00273959

C26/5/10

ឯកសារដើម
ORIGINAL DOCUMENT/DOCUMENT ORIGINAL
ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/Date de reception): 22 / 01 / 2009
ម៉ោង (Time/Heure): 16:00
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: C.A. Fuy

# អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
# នៅចំពោះមុខអង្គបុរេជំនុំជម្រះ

**សំណុំរឿងលេខ** ៖ ០២/១៩-០៩-២០០៧-អ.វ.ត.ក/ក.ស.ច.ស (អ.ប.ជ-១៥)

**កាលបរិច្ឆេទនៃការបញ្ជូន** ៖ ថ្ងៃទី២២ ខែមករា ឆ្នាំ២០០៩

**ភាគីបញ្ជូន** ៖ ការិយាល័យសហព្រះរាជអាជ្ញា

**ភាសាដើម** ៖ អង់គ្លេស

**ប្រភេទឯកសារ** ៖ សាធារណៈ (អត្ថបទត្រូវបានលុបចោលខ្លឹមសារមួយចំនួន)

---

## អត្ថបទត្រូវបានលុបចោលខ្លឹមសារមួយចំនួន នៃចម្លើយតបរបស់សហព្រះរាជអាជ្ញា នៅនឹងបណ្តឹងឧទ្ធរណ៍របស់ ខៀវ សំផន ប្រឆាំងនឹងដីកា សម្រេចអំពីការបន្តថិរវេលា នៃការឃុំខ្លួនបណ្តោះអាសន្នចុះថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ២០០៨

---

**បញ្ជូនដោយ៖**

**ការិយាល័យសហព្រះរាជអាជ្ញា៖**

លោកស្រី ជា លាង

លោក Robert PETIT

លោក យ៉េត ចរិយា

លោក William SMITH

លោក ពេជ្រ សម្បត្តិ

លោក Vincent de WILDE d'ESTMAEL

**ចែកចាយជូន៖**

**អង្គបុរេជំនុំជម្រះ៖**

ចៅក្រម ប្រាក់ គឹមសាន

ចៅក្រម ន័យ ថុល

ចៅក្រម ហួត វុទ្ធី

ចៅក្រម Katinka LAHUIS

ចៅក្រម Rowan DOWNING

**មេធាវីការពារក្តីរបស់ ខៀវ សំផន៖**

លោក ស សុវាន

លោកស្រី Jacques VERGÈS

ឯកសារបានថតចម្លងត្រឹមត្រូវតាមច្បាប់ដើម
CERTIFIED COPY/COPIE CERTIFIÉE CONFORME
ថ្ងៃ ខែ ឆ្នាំ នៃការបញ្ជាក់ (Certified Date/Date de certification): 26 / 01 / 2009
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: C.A. Fuy

# I. សេចក្តីផ្តើម

១. សហព្រះរាជអាជ្ញាសូមធ្វើការឆ្លើយតបទៅនឹងបណ្តឹងឧទ្ធរណ៍ របស់សហមេធាវីការពារក្តី ("បណ្តឹងឧទ្ធរណ៍")[1] ដាក់ថ្ងៃទី០៤ ខែធ្នូ ឆ្នាំ២០០៨ ដែលចង់ឲ្យមានការច្រានចោលនូវដីកាសម្រេចរបស់សហចៅក្រមស៊ើបអង្កេត អំពីការបន្តថិរវេលានៃការឃុំខ្លួនបណ្តោះអាសន្ន ជនត្រូវចោទ ខៀវ សំផន ("ជនត្រូវចោទ" ឬ "ម្ចាស់បណ្តឹងឧទ្ធរណ៍") បន្ថែមរយៈពេលមិនលើសពី១ឆ្នាំ ("ដីកាបន្តថិរវេលា")[2]។ មេធាវីការពារក្តីអះអាងថា ជនត្រូវចោទគួរត្រូវបានដោះលែង[3] ព្រោះ(១) សហចៅក្រមស៊ើបអង្កេត ("ស.ច.ស") មានកាតព្វកិច្ចពន្យាពេលការសម្រេចរបស់ខ្លួន (២) សហចៅក្រមស៊ើបអង្កេតលម្អៀង ហេតុដូច្នេះមិនអាចចេញដីកាសម្រេចអំពីការបន្តថិរវេលានៃការឃុំខ្លួនបណ្តោះអាសន្នបានឡើយ[4] (៣) សហចៅក្រមស៊ើបអង្កេតបានចេញសេចក្តីសម្រេចមិនចាំបាច់មួយ អំពីការបន្តថិរវេលានៃការឃុំខ្លួនបណ្តោះអាសន្ន ដោយគ្មានហេតុផលត្រឹមត្រូវ[5] និង(៤) ដីការសម្រេចអំពីការបន្តថិរវេលានៃការឃុំខ្លួនបណ្តោះអាសន្ន គឺសម្អាងទៅលើវិធានការណ៍ដែលមិនមានអត្ថិភាព[6]។

២. សហព្រះរាជអាជ្ញាសូមស្នើអង្គបុរេជំនុំជម្រះ មេត្តាច្រានចោលបណ្តឹងឧទ្ធរណ៍របស់មេធាវីការពារក្តី ផ្អែកលើមូលដ្ឋានដូចខាងក្រោម៖

---

[1] សំណុំរឿង ខៀវ សំផន សារណាបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេចអំពីការបន្តថេរៈវេលានៃការឃុំខ្លួនបណ្តោះអាសន្ន ថ្ងៃទី០៤ ខែធ្នូ ឆ្នាំ២០០៨ C២៦/៥/១ ERN ០០២៥១៧៨២-០០២៥១៧៩៨ (ភាសាអង់គ្លេស)(ចាប់ពីត្រឹមនេះតទៅហៅសម្គាល់ថា បណ្តឹងឧទ្ធរណ៍)។

[2] សំណុំរឿង ខៀវ សំផន ដីកាសម្រេចអំពីការបន្តថេរៈវេលានៃការឃុំខ្លួនបណ្តោះអាសន្ន ថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ២០០៨ C២៦/៤ ERN ០០២៥០៧៧៣-០០២៥០៧៨១ (ភាសាអង់គ្លេស) (ចាប់ពីត្រឹមនេះតទៅហៅសម្គាល់ថា ដីកាបន្តថិរវេលា)។

[3] បណ្តឹងឧទ្ធរណ៍ C២៦/៥/១ កថាខណ្ឌទី៦

[4] បណ្តឹងឧទ្ធរណ៍ C២៦/៥/១ កថាខណ្ឌទី៤

[5] បណ្តឹងឧទ្ធរណ៍ C២៦/៥/១ កថាខណ្ឌទី៥

[6] បណ្តឹងឧទ្ធរណ៍ C២៦/៥/១ កថាខណ្ឌទី៦

(ក) សហចៅក្រមស៊ើបអង្កេត គ្មានកាតព្វកិច្ចពន្យាពេលសេចក្តីសម្រេចរបស់ខ្លួនឡើយ។ ផ្ទុយទៅវិញ ពួកគេត្រូវធ្វើសេចក្តីសម្រេចអំពីការបន្តថិរវេលានៃការឃុំខ្លួនបណ្តោះអាសន្ន មុនពេលការឃុំខ្លួនបណ្តោះអាសន្នផុតកំណត់។

(ខ) នេះមិនមែនជាវេទិកាសម្រាប់ស្តាប់ការអះអាងរបស់ជនត្រូវចោទ លើកឡើងអំពីភាពមិនលម្អៀងរបស់សហចៅក្រមស៊ើបអង្កេតទេ ហើយការលើកឡើងសុទ្ធតែគ្មានមូលដ្ឋាន។ ផ្ទុយទៅវិញ ជនត្រូវចោទគួរដាក់ពាក្យបណ្តឹងផិតចិត្ត ក្រោមវិធាន៣៤ នៃវិធានផ្ទៃក្នុង ហើយវាក៏ជាបណ្តឹងដែលគ្មានមូលដ្ឋានដែរ។

(គ) ជនត្រូវចោទខកខានមិនបានបង្ហាញថាមានការប្រែប្រួលស្ថានភាពអង្គហេតុ ចាប់តាំងពីជនត្រូវចោទត្រូវបានសហចៅក្រមស៊ើបអង្កេតចាប់ឃុំខ្លួន ក្នុងមន្ទីរឃុំឃាំង នាថ្ងៃទី១៩ ខែវិច្ឆិកា ឆ្នាំ២០០៧ ("ដីកាឃុំខ្លួន")[7] ហើយចាប់តាំងពីសហចៅក្រមស៊ើបអង្កេតបានចេញដីកាសម្រេចបដិសេធការដោះលែងបណ្តោះអាសន្ន កាលពីថ្ងៃទី២៨ ខែតុលា ឆ្នាំ២០០៨[8]។ នៅក្នុងដីកាសម្រេចអំពីការបន្តថិរវេលានៃការឃុំខ្លួនបណ្តោះអាសន្ន ដែលបានវាយតម្លៃភស្តុតាងនៅលើសំណុំរឿងនោះ សហចៅក្រមស៊ើបអង្កេតបានកត់សម្គាល់ឃើញថា លក្ខខណ្ឌនៃវិធាន ៦៣ (៣) (ក) និង ៦៣ (៣) (ខ) (i) (ii) (iv) និង (v) ត្រូវបានបំពេញ ហើយការឃុំខ្លួនបណ្តោះអាសន្ន នៅតែជាវិធានការណ៍ចាំបាច់មួយ ឈរលើមូលដ្ឋានទាំងអស់នោះ[9]។

---

[7] សំណុំរឿងខៀវ សំផន ដីកាសម្រេចឃុំខ្លួនបណ្តោះអាសន្ន ថ្ងៃទី១៩ ខែវិច្ឆិកា ឆ្នាំ២០០៧ C២៦ ERN ០០១៥២៩៩១-៩៦ (ភាសាបារាំង) ០០១៥៦៧០០-០៥ (ភាសាអង់គ្លេស) និង០០១៥២៩៧៣-៧៨ (ភាសាខ្មែរ) (ចាប់ពីត្រឹមនេះតទៅ ហៅសម្គាល់ថា ដីកាឃុំខ្លួន)។

[8] សំណុំរឿងខៀវ សំផន ដីកាបដិសេធសំណើដោះលែង ថ្ងៃទី២៨ ខែតុលា ឆ្នាំ២០០៨ C៤០/៤ ERN ០០២៣៦២៦១-៧១ (ភាសាអង់គ្លេស) និងERN ០០២៣៥០៣៣-៤៤ (ភាសាបារាំង) (ចាប់ពីត្រឹមនេះតទៅ ហៅសម្គាល់ថា ការបដិសេធសំណើដោះលែង)។

[9] ដីកាបន្តថេរៈវេលា C២៦/៤ កថាខណ្ឌទី២៧។

(ឃ) នៅក្នុងតំណាក់កាលនៃការស៊ើបអង្កេតនេះ សំណុំរឿងបច្ចុប្បន្នមានភស្តុតាងដែលអាចធ្វើឱ្យអ្នកសង្កេតការណ៍មិនលម្អៀងជឿជាក់ថា ជនត្រូវចោទធ្លាប់បានប្រព្រឹត្តឧក្រិដ្ឋកម្ម ដែលកំពុងស្ថិតក្រោមការស៊ើបអង្កេតមែន។ បន្ថែមពីលើនេះលក្ខខណ្ឌផ្សេងៗគ្នាចំនួនបួន ក្នុងចំណោមលក្ខខណ្ឌទាំងប្រាំ ដែលចាំបាច់សម្រាប់ការឃុំខ្លួនក្រោមវិធាន ៦៣ (៣) (ខ) ត្រូវបានបំពេញធ្វើឱ្យការឃុំខ្លួនបណ្តោះអាសន្នមានយុត្តិកម្ម។ ជាពិសេសការឃុំខ្លួនជនត្រូវចោទ គឺនៅតែជាវិធានការណ៍ចាំបាច់មួយ (១) ដើម្បីការពារជនរងគ្រោះ និងសាក្សី (២) ដើម្បីថែរក្សាភស្តុតាង និងការការពារកុំឱ្យមានការបំផ្លាញភស្តុតាង (៣) ដើម្បីការពារសន្តិសុខជនត្រូវចោទ និង(៤) ដើម្បីថែរក្សាសណ្តាប់ធ្នាប់សាធារណៈ។

## II. **សាវតានីតិវិធីពាក់ព័ន្ធ**

៣. កាលពីថ្ងៃទី១៨ ខែកក្កដា ឆ្នាំ២០០៧ សហព្រះរាជអាជ្ញា បានដាក់ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ ដែលបានរៀបរាប់អំពីអង្គហេតុ និងឈ្មោះជនត្រូវចោទ និងជនសង្ស័យបួននាក់ផ្សេងទៀត ថាជាអ្នកទទួលខុសត្រូវឧក្រិដ្ឋកម្មមួយចំនួន ក្រោមយុត្តាធិការតុលាការនេះ។ កាលពីថ្ងៃទី១៨ ខែតុលា ឆ្នាំ២០០៧ សហព្រះរាជអាជ្ញាបានដាក់ "ភស្តុតាង និងឯកសារសម្អាងផ្លូវច្បាប់បន្ថែម គាំទ្រមូលដ្ឋាននៃការឃុំខ្លួនបណ្តោះអាសន្នជនសង្ស័យ"[10] ។ ជនត្រូវចោទត្រូវបានចាប់ខ្លួនកាលពីថ្ងៃទី១៩ ខែវិច្ឆិកា ឆ្នាំ២០០៧ និងត្រូវបាននាំខ្លួនមកជួបសហចៅក្រមស៊ើបអង្កេតសម្រាប់ការបង្ហាញខ្លួនដំបូង[11] និងសវនាការតទល់មួយ[12] និងត្រូវ

---

[10] សំណុំរឿងខៀវ សំផន ដីកាជូនដំណឹងអំពីការធ្វើឱ្យគេដឹងឮអំពីភស្តុតាង និងតារាងឯកសារសម្អាងផ្លូវច្បាប់គាំទ្រដល់មូលដ្ឋានសម្រាប់ការឃុំខ្លួនបណ្តោះអាសន្នជនសង្ស័យ ថ្ងៃទី១៨ ខែតុលា ឆ្នាំ២០០៧ D២៩ និង D២៩/១ ERN ០០១៤៨៩០២-០៤ និង ០០១៤៨៩៦៥-០០១៤៩៨៤១ (ភាសាអង់គ្លេស) រាប់ទាំងឯកសារអង្គហេតុចំនួន៣៣ ពាក់ព័ន្ធនឹងខៀវ សំផន ក្នុងឧបសម្ព័ន្ធ ក (ERN ០០១៤៩៣៤០-០០១៤៩៥៦៦-ភាសាអង់គ្លេស)។

[11] សំណុំរឿង ខៀវ សំផន កំណត់ហេតុលាយលក្ខណ៍អក្សរអំពីការចូលបង្ហាញខ្លួនដំបូង ស.ច.ក ថ្ងៃទី១៩ ខែវិច្ឆិកា ឆ្នាំ២០០៧ D៤២ ERN០០១៥៣៣១៩-០០១៥៣៣២២ (ភាសាអង់គ្លេស) ០០១៥៣៣៣៣-៣៦ (ភាសាបារាំង) និង ០០១៥៣៣០៤-០៨ (ភាសាខ្មែរ)។

បានចោទពីបទឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ និងការរំលោភធ្ងន់ធ្ងរទៅលើសអនុសញ្ញាក្រុងហ្សឺណែវ ថ្ងៃទី១២ ខែសីហា ឆ្នាំ១៩៤៩[13]។ សហចៅក្រមស៊ើបអង្កេតបានចេញដីកាសម្រេចឃុំខ្លួនជនត្រូវចោទជាបណ្ដោះអាសន្នសម្រាប់រយៈពេលមិនលើស១ឆ្នាំ (ដីកាឃុំខ្លួន) កាលពីថ្ងៃទី១៩ ខែវិច្ឆិកា ឆ្នាំ ២០០៧[14]។ មេធាវីការពារក្ដី បានប្ដឹងឧទ្ធរណ៍សេចក្ដីសម្រេចនេះតាមរយៈការដាក់សេចក្ដីសន្និដ្ឋានជាលាយលក្ខណ៍អក្សរមួយ កាលពីថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០០៧ ផ្អែកតាមវិធានផ្ទៃក្នុង វិធាន ៦៣(៣)(ក) ("វិធាន")។ សហព្រះរាជអាជ្ញាបានដាក់ចម្លើយតបរបស់ខ្លួន ទៅនឹងបណ្ដឹងឧទ្ធរណ៍ កាលពីថ្ងៃទី០៦ ខែកុម្ភៈ ឆ្នាំ២០០៨ ហើយភាគីដើមបណ្ដឹងរដ្ឋប្បវេណីដាក់កាលពីថ្ងៃទី១៧ ខែមេសា ឆ្នាំ២០០៨[15]។ អង្គបុរេជំនុំជម្រះបានបើកសវនាការកាលពីថ្ងៃទី២៣ ខែមេសា ឆ្នាំ២០០៨ ដែលសវនាការនេះត្រូវបានលើកពេល "ដែលបណ្ដាលមកពីអាកប្បកិរិយានៃសហមេធាវីអន្តរជាតិ" ដែលត្រូវទទួលការព្រមាន ដោយអង្គបុរេជំនុំជម្រះ អនុលោមតាមវិធាន៣៨[16]។ កាលពីថ្ងៃទី២២ ខែកក្កដា ឆ្នាំ២០០៨ មេធាវីការពារក្ដីបាន

---

[12] សំណុំរឿង ខៀវ សំផន កំណត់ហេតុលាយលក្ខណ៍អក្សរអំពីសវនាការតទល់ ស.ច.ក ថ្ងៃទី១៩ ខែវិច្ឆិកា ឆ្នាំ២០០៧ C២៥ ERN ០០១៥៣២៦៦-០០១៥៣២៧០ (ភាសាអង់គ្លេស) ០០១៥៣២៩៦-០០១៥៣៣០១ (ភាសាបារាំង) និង ០០១៥៣២២៨-០០១ ៥៣២៣៥ (ភាសាខ្មែរ)។

[13] នៅថ្ងៃដដែល សហព្រះរាជអាជ្ញាបានដាក់មូលដ្ឋានបន្ថែមគាំទ្រការឃុំខ្លួនបណ្ដោះអាសន្ន៖ សំណុំរឿង ខៀវ សំផន មូលដ្ឋានបន្ថែមរបស់សហព្រះរាជអាជ្ញាគាំទ្រដល់ការឃុំខ្លួនបណ្ដោះអាសន្ន ក្នុងសំណុំរឿងជនសង្ស័យ ខៀវ សំផន ថ្ងៃទី១៩ ខែវិច្ឆិកា ឆ្នាំ២០០៧ C២៨ ERN ០០១ ៥៣០៥០-០០១ ៥៣០៦៥ (ភាសាខ្មែរ) ០០១ ៥៣០៤១-០០១ ៥៣០៤៩ (ភាសាអង់គ្លេស) និង០០១៦៦៦៣៥-០០១៦៦៦៤៣ (ភាសាបារាំង)។

[14] ដីកាឃុំខ្លួន C២៦។

[15] សំណុំរឿង ខៀវ សំផន សារណាបណ្ដឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេចឃុំខ្លួនបណ្ដោះអាសន្ន ថ្ងៃទី១៩ ខែវិច្ឆិកា ឆ្នាំ២០០៧ ថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០០៧ C២៦/I/៣ ERN ០០១៥៨៣០៣-១៤ (ភាសាអង់គ្លេស) ចម្លើយតបរបស់សហព្រះរាជអាជ្ញា ទៅកាន់បណ្ដឹងឧទ្ធរណ៍របស់ខៀវ សំផន ប្រឆាំងនឹងដីកាសម្រេចឃុំខ្លួន បណ្ដោះអាសន្ន ថ្ងៃទី១៩ ខែវិច្ឆិកា ឆ្នាំ២០០៧ ថ្ងៃទី០៦ ខែកុម្ភៈ ឆ្នាំ២០០៨ C២៦/I/៩ ERN ០០១៦០៧៦៧-៩៥ (ភាសាអង់គ្លេស) ចម្លើយតបរួមរបស់សហមេធាវីភាគីដើមបណ្ដឹងរដ្ឋប្បវេណី ទៅនឹងបណ្ដឹងឧទ្ធរណ៍ របស់ខៀវ សំផន ប្រឆាំងនឹងដីកាសម្រេចឃុំខ្លួនបណ្ដោះអាសន្ន ថ្ងៃទី១៨ ខែមេសា ឆ្នាំ២០០៨ C២៦/I/២១ ERN ០០១៧៨២០៥-៥២ (ភាសាអង់គ្លេស)។

[16] សំណុំរឿង ខៀវ សំផន សេចក្ដីសម្រេចអ.ប.ជ ស្ដីពីការដាក់ពាក្យសុំពន្យាពេលសវនាការស្ដីពីបណ្ដឹងឧទ្ធរណ៍ប្រឆាំងនឹងការឃុំខ្លួនបណ្ដោះអាសន្ន ចុះថ្ងៃទី២៣ ខែមេសា ឆ្នាំ២០០៨ C២៦/I/២៥ ERN ០០១៨០៣៤១-៤៤ (ភាសាអង់គ្លេស) កំណត់ហេតុលាយល័ក្ខអក្សររបស់អ.ប.ជ ស្ដីពីសវនាការថ្ងៃទី២៣ ខែមេសា ឆ្នាំ២០០៨ ស្ដីពីបណ្ដឹងឧទ្ធរណ៍ប្រឆាំងនឹង

ដាក់បណ្តឹងឧទ្ធរណ៍នៅចំពោះមុខ អ.ប.ជ ប្រឆាំងនឹងដីកាស្តីពីសិទ្ធិបកប្រែ និងកាតព្វកិច្ចនៃគូភាគី ដែលនៅមិនទាន់សម្រេចនៅឡើយ[17]។ នៅថ្ងៃទី០៨ ខែតុលា ឆ្នាំ២០០៨ មេធាវីការពារក្តីបានដកបណ្តឹងឧទ្ធរណ៍របស់ខ្លួនប្រឆាំងនឹងដីកាសម្រេចឃុំខ្លួនបណ្តោះអាសន្ន[18] និងបានដាក់ពាក្យសុំបន្ទាន់មួយដើម្បីឱ្យមានការដោះលែង ទៅកាន់សហចៅក្រមស៊ើបអង្កេតអនុលោមតាមវិធាន ៦៤ (២)[19] ដែលត្រូវបានសហចៅក្រមស៊ើបអង្កេតបដិសេធចោល នាថ្ងៃទី២៨ ខែតុលា ឆ្នាំ២០០៨[20]។ មេធាវីការពារក្តីបានដាក់បណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេចបដិសេធលើសំណើសុំដោះលែង នាថ្ងៃទី២៧ ខែវិច្ឆិកា ឆ្នាំ២០០៨[21]។ ដោយអនុលោមតាមវិធាន ៦៣ (៧) កាលពីថ្ងៃទី២៨ ខែតុលា ឆ្នាំ២០០៨ សហចៅក្រមស៊ើបអង្កេតបានជូនដំណឹងដល់ជនត្រូវចោទ និងមេធាវី ថាខ្លួនកំពុងពិចារណាអំពីការបន្តថិរវេលានៃការឃុំខ្លួន

---

ដីកាសម្រេចឃុំខ្លួនបណ្តោះអាសន្ន ថ្ងៃទី០២ ខែឧសភា ឆ្នាំ២០០៨ C២៦/I/២៥ ERN ០០១៨៥៥៣៤-៤១ (ភាសាអង់គ្លេស)។

[17] សំណុំរឿង ខៀវ សំផន បណ្តឹងឧទ្ធរណ៍នៃមេធាវីការពារក្តី ប្រឆាំងនឹងសេចក្តីសម្រេចបដិសេធសំណើបកប្រែសំណុំរឿង ខៀវ សំផន ថ្ងៃទី២២ ខែកក្កដា ឆ្នាំ២០០៨ A១៩០/I/១ ERN ០០២១២៣៣៤-៥២ (ភាសាអង់គ្លេស) និង ០០២០៧៤១១-២៩ (ភាសាបារាំង) ដីកាស.ច.ក ស្តីពីសិទ្ធិបកប្រែ និងកាតព្វកិច្ចនៃភាគីទាំងឡាយ ចុះថ្ងៃទី១៩ ខែមិថុនា ឆ្នាំ ២០០៨ A១៩០ ERN ០០១៩៦៩២៣-៣០ (ភាសាអង់គ្លេស)។

[18] សំណុំរឿង ខៀវ សំផន ដីកាជូនដំណឹងរបស់មេធាវីការពារក្តី អំពីការដកបណ្តឹងឧទ្ធរណ៍ ថ្ងៃទី០៨ ខែតុលា ឆ្នាំ២០០៨ C២៦/I/៣០ ERN ០០២២៨៧៨៧-០០២២៨៧៩៣ (ភាសាបារាំង) 00231936-៤២ (ភាសាអង់គ្លេស) សេចក្តីសម្រេចរបស់អ.ប.ជ ទាក់ទិននឹងដីកាជូនដំណឹងអំពីការដកបណ្តឹងឧទ្ធរណ៍ ចុះថ្ងៃទី១៥ ខែតុលា ឆ្នាំ២០០៨ C២៦/I/៣១ ERN ០០២៣១៩៧១-៧៤ (ភាសាអង់គ្លេស)។

[19] សំណុំរឿង ខៀវ សំផន ការដាក់បណ្តឹងបន្ទាន់របស់មេធាវីការពារក្តី សុំឱ្យមានការដោះលែង ចុះថ្ងៃទី០៨ ខែតុលា ឆ្នាំ២០០៨ C៤០ ERN ០០២២៨៩០៦-១៨។

[20] ដីកាសម្រេចបដិសេធសំណើសុំដោះលែង C៤០/៤ សូមមើល ចម្លើយតបរបស់សហព្រះរាជអាជ្ញាទៅនឹងការដាក់ដីកាទាក់ទងនឹងការដាក់បណ្តឹងបន្ទាន់សុំដោះលែង របស់សហចៅក្រមស៊ើបអង្កេត ចុះថ្ងៃទី២៤ ខែតុលា ឆ្នាំ២០០៨ C៤០/៣ ERN ០០២៣៤៦៣១-៤៥ (ភាសាអង់គ្លេស)។

[21] សំណុំរឿង ខៀវ សំផន, សារណាឧទ្ធរណ៍ប្រឆាំងនឹងដីកាបដិសេធដោះលែងបណ្តោះអាសន្ន, ចុះថ្ងៃទី២៨ ខែវិច្ឆិកា ឆ្នាំ២០០៨, C៤០/៥/១ ERN ០០២៤២៩៤៩-៦៨ (ភាសាបារាំង), ERN ០០២៦៩៨៦៥-៨២ (ភាសាអង់គ្លេស)។

បណ្ដោះអាសន្ន និងបានស្នើពួកគេឱ្យដាក់ការអង្កេតរបស់ពួកគេក្នុងអំឡុងពេល១៥ថ្ងៃ[22]។ ពួកគេបានដាក់ការអង្កេត នៅថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ២០០៨[23]។ ចុងក្រោយ សហចៅក្រមស៊ើបអង្កេត បានចេញដីកាសម្រេចអំពីការបន្តថិរវេលានៃការឃុំខ្លួនបណ្ដោះអាសន្ន កាលពីថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ២០០៨[24]។ មេធាវីការពារក្ដីបានដាក់បណ្ដឹងឧទ្ធរណ៍ កាលពីថ្ងៃទី០៥ ខែធ្នូ ឆ្នាំ២០០៨[25]។ នាថ្ងៃទី០៨ ខែមករា ឆ្នាំ២០០៩ អ.ប.ជ បានណែនាំសហព្រះរាជអាជ្ញាឱ្យដាក់សារណាតបរបស់ពួកគេត្រឹមថ្ងៃទី០៩ ខែមករា ឆ្នាំ២០០៩[26]។

## III. ដីកាសន្និដ្ឋានបឋម

### *សវនាការផ្ទាល់មាត់មិនមែនជាការចាំបាច់ទេ*

៥. វិធាន ៧៧ (៣) បានអនុញ្ញាតឱ្យ អ.ប.ជ កំណត់លើបណ្ដឹងឧទ្ធរណ៍ ដោយផ្អែកលើសារណាជាលាយលក្ខណ៍អក្សរតែប៉ុណ្ណោះ បន្ទាប់ពីបានពិចារណាទស្សនៈនៃភាគីទាំងឡាយ។ ម្ចាស់បណ្ដឹងឧទ្ធរណ៍ពុំបានស្នើសុំឱ្យមានសវនាការផ្ទាល់មាត់ នៃបណ្ដឹងឧទ្ធរណ៍នេះឡើយ។ ទោះបីជាសហព្រះរាជអាជ្ញាគាំទ្រសវនាការផ្ទាល់មាត់សម្រាប់បណ្ដឹងឧទ្ធរណ៍ក៏ដោយ ក៏ប៉ុន្តែឧទ្ធរណ៍មួយនេះ ទាក់ទងតែទៅនឹងការបន្តថិរវេលានៃការឃុំខ្លួន ហើយបណ្ដឹងឧទ្ធរណ៍នេះ

---

[22] សំណុំរឿង ខៀវ សំផន ការជូនដំណឹងរបស់សហចៅក្រមស៊ើបអង្កេត អនុលោមតាមវិធាន ៦៣ (៧) នៃវិធានផ្ទៃក្នុង ចុះថ្ងៃទី២៨ ខែតុលា ឆ្នាំ២០០៨ C២៦/២ ERN ០០២៣៥៤០០-០១ (ភាសាបារាំង)។

[23] សំណុំរឿង ខៀវ សំផន Objections de la Défense concernant la prolongation de la detention ចុះថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ ២០០៨ C២៦/៣ ERN ០០២៣៨៩៣០-៤១ (ភាសាបារាំង) មកទល់ពេលនេះ ពុំមានឯកសារបកប្រែជាភាសាអង់គ្លេសទេ។

[24] ដីកាបន្តថេរៈវេលា C២៦/៤ ERN ០០២៥០៧៧៣-៨១ (ភាសាអង់គ្លេស)។

[25] បណ្ដឹងឧទ្ធរណ៍ C២៦/៥/១ បណ្ដឹងឧទ្ធរណ៍នេះត្រូវបានជូនដំណឹងទៅសហព្រះរាជអាជ្ញា ជាភាសាអង់គ្លេស នាថ្ងៃទី២៣ ខែធ្នូ ឆ្នាំ២០០៨។ សហព្រះរាជអាជ្ញាបានដាក់បណ្ដឹងសុំពន្យាពេលដាក់ចម្លើយតបរបស់ខ្លួន នាថ្ងៃទី២៩ ខែធ្នូ C២៦/៥/៦ ERN ០០២៦៧៩០៦-០៩ (ភាសាអង់គ្លេស)។

[26] សំណុំរឿង ខៀវ សំផន សេចក្ដីសម្រេចស្ដីពីការដាក់បណ្ដឹងសុំពន្យាពេលវេលាដាក់ចម្លើយតប ទៅនឹងបណ្ដឹងឧទ្ធរណ៍របស់ ខៀវ សំផន ប្រឆាំងនឹងដីកាសម្រេចអំពីការបន្តថេរៈវេលានៃការឃុំខ្លួនបណ្ដោះអាសន្ន ចុះថ្ងៃទី ០៨ ខែមករា ឆ្នាំ២០០៩, C២៦/៥/៩, ERN ០០២៦៩៧៩០-៩២ (ភាសាអង់គ្លេស)។

00273966



ពុំបានលើកអំណះអំណាងអង្គហេតុ ឬអង្គច្បាប់ថ្មីៗដែលចាំបាច់ សម្រាប់សវនាការផ្ទាល់មាត់ទេ។ ហេតុដូច្នេះ ដើម្បីជាផលប្រយោជន៍សេដ្ឋកិច្ចរបស់តុលាការ ពួកគេបានស្នើសុំឱ្យអ.ប.ជ សម្រេចលើបណ្តឹងឧទ្ធរណ៍នេះ តាមរយៈការធ្វើសេចក្តីសន្និដ្ឋានជាលាយលក្ខណ៍អក្សរជាការស្រេច។

## IV. ច្បាប់

### *ភារកិច្ចត្រូវផ្តល់សម្អាងហេតុ នៅក្នុងដីកាសម្រេចឃុំខ្លួនបណ្តោះអាសន្ន*

៥. វិធាន ៦៣(៧) តម្រូវឱ្យសហចៅក្រមស៊ើបអង្កេត "បញ្ជាក់សម្អាងហេតុ" សម្រាប់ការបន្តថេរៈវេលានៃការឃុំខ្លួនបណ្តោះអាសន្ន។ សម្អាងហេតុទាំងនេះ ត្រូវតែបានផ្តល់ឱ្យក្រោយពីពិចារណាសំណុំរឿង និងការជំទាស់របស់អ្នកជាប់ឃុំ[27]។ ដោយលើកឡើងអំពីច្បាប់យុត្តិសាស្ត្រអន្តរជាតិ អ.ប.ជបានរកឃើញថាសេចក្តីសម្រេចទាំងអស់ របស់ស្ថាប័នតុលាការរាប់ទាំងសហចៅក្រមស៊ើបអង្កេតផង ត្រូវបានផ្តល់សម្អាងហេតុ ដើម្បីបំពេញនិយាមអន្តរជាតិ[28]។

៦. អ.ប.ជ បានកំណត់ថា កាតព្វកិច្ចក្នុងការបញ្ជាក់សម្អាងហេតុ គឺគ្រាន់តែជាការតម្រូវឱ្យសហចៅក្រមស៊ើបអង្កេត បញ្ជាក់អំពីមូលដ្ឋានអង្គច្បាប់ និងអង្គហេតុ ទាំងឡាយដែលបានលើកយកមកពិចារណា មុនពេលឈានដល់ការចេញសេចក្តីសម្រេច។ សហចៅក្រមស៊ើបអង្កេតអាចបំពេញកាតព្វកិច្ចនេះ"តាមរយៈការនិយាយសំដៅទៅដល់សំណុំរឿងនេះជាទូទៅ និងកាលៈទេសៈផ្សេងៗទៀត" ដោយសារសហចៅក្រមស៊ើបអង្កេត គ្មានកាតព្វកិច្ចបង្ហាញការ

---

[27] អនុលោមតាមវិធាន៦៣ (៧) កិច្ចដំណើរការនីតិវិធីនៃការបន្តថេរៈវេលាឃុំខ្លួន កើតឡើងរវាងតែស.ច.ក និងជនត្រូវចោទ ដោយសារតែមុនពេលបន្តថេរៈវេលានៃការឃុំខ្លួនបណ្តោះអាសន្ន ស.ច.ក ឮតែការជំទាស់របស់ជនត្រូវចោទប៉ុណ្ណោះ។ គ្មានឃើញភាគីផ្សេងណាពាក់ព័ន្ធក្នុងដំណើរការនេះទេ។ ដូច្នេះដំណើរការនៃការបន្តថេរៈវេលាឃុំខ្លួនបណ្តោះអាសន្ន ក្រោមវិធាន ៦៣ (៧) មានភាពខុសគ្នាពីដំណើរការនៃការឃុំខ្លួនដំបូង ក្រោមវិធាន ៦៣ (៣) ដែលរាប់បញ្ចូលទាំងសវនាការតទល់នៅចំពោះមុខ ស.ច.ក ផង។

[28] សំណុំរឿង នួន ជា សេចក្តីសម្រេចស្តីពីបណ្តឹងឧទ្ធរណ៍របស់នួន ជា ប្រឆាំងនឹងដីកាសម្រេចបដិសេធសំណើសុំមោឃភាព ចុះថ្ងៃទី២៨ ខែសីហា ឆ្នាំ២០០៨ សំណុំរឿងលេខ ០០២/១៩-០៩-២០០៧-អ.វ.ត.ក-ក.ស.ច.ស (អ.ប.ជ ០៦) D ៥៥/I/៨ ENR ០០១៦១៩៣២២-៣៣ (ភាសាអង់គ្លេស) កថាខណ្ឌទី២១។

យល់ឃើញអំពីកត្តាទាំងអស់នោះ[29]។ ក្នុងដីកាសម្រេចអំពីការបន្តថេរៈវេលានៃការឃុំខ្លួនបណ្តោះអាសន្ន មានសម្អាងហេតុគ្រប់គ្រាន់ និងសមល្មមហើយ។

## *លក្ខខណ្ឌចាំបាច់នាំឱ្យមានការឃុំខ្លួន*

៧. ក្រោមវិធាន ៦៣ (៣) សហចៅក្រមស៊ើបអង្កេត អាចចេញដីកាសម្រេចឃុំខ្លួនបណ្តោះអាសន្ន ពេល៖

(ក) មានភស្តុតាងគួរឱ្យជឿជាក់ថាជនត្រូវចោទ ប្រហែលបានប្រព្រឹត្តឧក្រិដ្ឋកម្ម ដូចដែលបានបញ្ជាក់នៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ។

(ខ) ពិចារណាឃើញថាការឃុំខ្លួនបណ្តោះអាសន្ន គឺជាវិធានការណ៍ចាំបាច់មួយដើម្បី

- (i) រារាំងកុំឱ្យជនដែលត្រូវចោទគាបសង្កត់ទៅលើសាក្សី ឬជនរងគ្រោះ ឬរារាំងការត្រូវរ៉ូវគ្នារវាងជនត្រូវចោទ និងអ្នកសមគំនិត។
- (ii) ថែរក្សាភស្តុតាង ឬការពារមិនឱ្យបំផ្លាញភស្តុតាង។
- (iii) ធានាអំពីវត្តមានរបស់ជនត្រូវចោទនៅក្នុងដំណើរការនីតិវិធី។
- (iv) ការពារសន្តិសុខឱ្យជនដែលត្រូវចោទ ឬ
- (v) ថែរក្សាសណ្តាប់ធ្នាប់សាធារណៈ។

---

[29] សំណុំរឿង អៀង សារី សេចក្តីសម្រេចអំពីបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាឃុំខ្លួនបណ្តោះអាសន្ន របស់អៀង សារី សំណុំរឿងលេខ ០០២/១៩-០៩-២០០៧-អ.វ.ត.ក-ក.ស.ច.ស (អ.ប.ជ ០៣) ចុះថ្ងៃទី១៧ ខែតុលា ឆ្នាំ២០០៨ C២២/I/៧៤ ERN ០០២៣២៩៧៦-០០៤ (ភាសាអង់គ្លេស) កថាខណ្ឌទី៦៤-៦៦ (ចាប់ពីត្រឹមនេះតទៅ ហៅសម្គាល់ថា សេចក្តីសម្រេចបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងការឃុំខ្លួន អៀង សារី) សូមមើល ច្បាប់យុត្តិសាស្ត្រ ICTY: រដ្ឋអាជ្ញា ទល់នឹង Popovic សេចក្តីសម្រេចស្តីពីបណ្តឹងឧទ្ធរណ៍ចាត់របៀបរបស់មេធាវីការពារក្តី អំពីសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងបដិសេធការដោះលែងបណ្តោះអាសន្ន Ljubomir Boroycanin សំណុំរឿងលេខ IT-០៥-៨៨-AR៦៥.២ អង្គជំនុំជម្រះសាលាឧទ្ធរណ៍ ថ្ងៃទី០១ ខែមីនា ឆ្នាំ២០០៧ កថាខណ្ឌ១៣ រដ្ឋអាជ្ញា ទល់នឹង Haradinaj សេចក្តីសម្រេចស្តីពីបណ្តឹងសុំដោះលែងបណ្តោះអាសន្នរបស់Lahi Brahimaj សំណុំរឿងលេខ IT-០៤-៨៤-PT អង្គជំនុំជម្រះសាលាដំបូង ICTY ថ្ងៃទី០៣ ខែឧសភា ឆ្នាំ២០០៦ កថាខណ្ឌទី១៦។

៨. លក្ខខណ្ឌទាំងប្រាំ នៃការឃុំខ្លួន ក្រោមវិធាន៦៣ (៣) (ខ) គឺបែកចេញដាច់ដោយឡែកពីគ្នា[30]។ គ្មានលក្ខខណ្ឌទាមទារថារាល់មូលដ្ឋាននីមួយៗត្រូវបានបំពេញនោះទេ មុនពេលសហចៅក្រមស៊ើបអង្កេត ពិចារណាថាការឃុំខ្លួនបណ្តោះអាសន្នគឺជាវិធានការណ៍ចាំបាច់ ឬពិចារណាថា ការបន្តថិរវេលានៃការឃុំខ្លួនបណ្តោះអាសន្នត្រូវបានធានា។ ផ្ទុយមកវិញ ប្រសិនបើពួកគេពិចារណាថាការឃុំខ្លួនមានត្រូវលក្ខខណ្ឌណាមួយ នៃលក្ខខណ្ឌទាំងប្រាំនោះ នោះលក្ខខណ្ឌនៃការឃុំខ្លួនត្រូវបានបំពេញហើយ។ វិធីសាស្ត្រនេះត្រូវបានអនុវត្ត នៅចំពោះមុខតុលាការព្រហ្មទណ្ឌផ្សេងទៀត សម្រាប់កាត់សេចក្តីឧក្រិដ្ឋកម្មអន្តរជាតិធ្ងន់ធ្ងរ ប្រហាក់ប្រហែលនេះដែរ[31]។

## *ការអនុវត្តន៍ឆន្ទានុសិទ្ធិ ក្នុងការពិចារណាអំពីការឃុំខ្លួន*

៩. ចៅក្រម ឬអង្គជំនុំជម្រះ មានឆន្ទានុសិទ្ធិ ក្នុងការសម្រេចអំពីឃុំខ្លួនបណ្តោះអាសន្នថាជាវិធានការណ៍ចាំបាច់ ឬការបន្តថេរៈវេលានៃការឃុំខ្លួនបណ្តោះអាសន្នត្រូវធានាឲ្យមាន។ ឆន្ទានុសិទ្ធិនេះ ជាធម្មតាត្រូវបានអនុវត្តដោយពិចារណាទៅលើឯកសារទាំងអស់ នៃសំណុំរឿង និងអង្គហេតុពាក់ព័ន្ធរបស់សំណុំរឿង រាប់ទាំងទម្ងន់នៃបទចោទ ភាពគួរឲ្យជឿជាក់នៃភស្តុតាង បុគ្គលិកលក្ខណៈនិងអាកប្បកិរិយាបច្ចុប្បន្ន និងអតីតកាលរបស់ជនត្រូវចោទ ផលប្រយោជន៍សាក្សី និងជនរងគ្រោះ និងផលប្រយោជន៍យុត្តិធម៌ទាំងមូល[32]។ នេះជាការស្របទៅតាម

[30] សេចក្តីសម្រេចស្តីពីបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងការឃុំខ្លួន អៀង សារី C២២/I/៧៤ កថាខណ្ឌទី១២១។

[31] រដ្ឋអាជ្ញា ទល់នឹង Sainovic និង Odjanic សេចក្តីសម្រេចបដិសេធការចាកចេញរបស់Odjanic ទៅឧទ្ធរណ៍សំណុំរឿងលេខ IT-៩៩-៣៧-AR៦៥.២ អង្គជំនុំជម្រះសាលាឧទ្ធរណ៍ ICTY ថ្ងៃទី២៧ ខែកក្កដា ឆ្នាំ២០០៣ ទំព័រទី៣ ERN ០០១៥៤០៣៩-៤២) និងត្រូវបានអនុម័តដោយអ.ប.ជ អ.វ.ត.ក សំណុំរឿងកាំង ហ្គេកអៀវ ហៅឌុច សេចក្តី សម្រេចអំពីបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងការឃុំខ្លួនបណ្តោះអាសន្ន របស់កាំង ហ្គេកអៀវ ហៅឌុច ចុះថ្ងៃទី០៣ ខែធ្នូ ឆ្នាំ២០០៧ សំណុំរឿងលេខ ០០១/១៨-០៧-២០០៧-អ.វ.ត.ក-ក.ស.ច.ស (អ.ប.ជ ០១) C៥/៤៥ ERN ០០១៥៤២៨៤-៣០២ (ភាសាអង់គ្លេស) កថាខណ្ឌទី៥៩ (ត្រឹមនេះតទៅហៅសម្គាល់ថា សេចក្តីសម្រេចបណ្តឹងឧទ្ធរណ៍អំពីការឃុំខ្លួន ឌុច)។

[32] រដ្ឋអាជ្ញា ទល់នឹង *Ljube Boskoski និង Johan Tarculovski* សេចក្តីសម្រេចស្តីពីបណ្តឹងឧទ្ធរណ៍ចាត់របៀបរបស់ Tarculoyski ស្តីពីការដោះលែងបណ្តោះអាសន្ន សំណុំរឿងលេខ IT-០៤-៨២-AR៦៥.២ អង្គជំនុំជម្រះសាលាឧទ្ធរណ៍ ICTY ថ្ងៃទី២៧ ខែកក្កដា ឆ្នាំ២០០៧ កថាខណ្ឌទី០៤ ERN ០០១៥៣៩៤៦-៥៤។

ការអនុវត្តន៍ដែលត្រូវបានគេទទួលយកក្នុងតុលាការព្រហ្មទណ្ឌអន្តរជាតិដែល អ.វ.ត.ក បានសម្រេចដើរតាម[33]។

## V. **អង្គហេតុ និងនីតិវិធី**

១០. មេធាវីការពារក្ដីបានលើកអំណះអំណាងថា សហចៅក្រមស៊ើបអង្កេតមានកាតព្វកិច្ច ពន្យាពេលការសម្រេចរបស់ខ្លួន (i) ពីព្រោះកិច្ចដំណើរការនីតិវិធីត្រូវបានធ្វើមានខ្វះចន្លោះ និងត្រូវបានពន្យាពេល (ii) ដោយសារតែមានភាពមិនប្រក្រតីដែលពាក់ព័ន្ធនឹងបញ្ហានៃការឃុំខ្លួន (iii) ពីព្រោះសហចៅក្រមស៊ើបអង្កេតគ្មានលទ្ធភាពចេញដីកា បន្តថិរវេលានៃការឃុំខ្លួនបណ្ដោះអាសន្នដោយមិនលម្អៀង។

**ក. សហចៅក្រមស៊ើបអង្កេតគ្មានកាតព្វកិច្ចពន្យាពេលការសម្រេចរបស់ខ្លួនឡើយ ប៉ុន្តែមានកាតព្វកិច្ចធ្វើសេចក្ដីសម្រេចអំពីការបន្តថិរវេលានៃការឃុំខ្លួនបណ្ដោះអាសន្ន។**

១១. មេធាវីការពារក្ដីបានបញ្ជាក់ថា សហចៅក្រមស៊ើបអង្កេតមានកាតព្វកិច្ចពន្យាពេលការចេញដីកានោះ ដោយរង់ចាំរហូតដល់ពេលអ.ប.ជ បានឈានដល់ការសម្រេចបណ្ដឹងឧទ្ធរណ៍ ស្ដីពីការបកប្រែឯកសារភស្តុតាង[34]។

១២. សហព្រះរាជអាជ្ញាសន្និដ្ឋានថាការស្នើពន្យាពេលចេញដីកានោះ គឺផ្អែកទាំងស្រុងទៅលើបញ្ហានានា ដែលអ.ប.ជ មិនទាន់បានពិភាក្សាសម្រេចនៅឡើយ។ ទាំងសហចៅក្រមស៊ើបអង្កេត និងអ.ប.ជ មិនដែលបានសន្និដ្ឋានថា សិទ្ធិជនត្រូវចោទត្រូវបានរំលោភដោយការខកខានមិនដែលបានបកប្រែឯកសារ សំណុំរឿង និង/ឬមិនដែលបានសន្និដ្ឋានថា ការឃុំខ្លួនបណ្ដោះអាសន្ននេះ

---

[33] សេចក្ដីសម្រេចបណ្ដឹងឧទ្ធរណ៍អំពីការឃុំខ្លួនឌុច C៥/៤៥ កថាខណ្ឌទី២៧។

[34] បណ្ដឹងឧទ្ធរណ៍អំពីការបកប្រែ A១៩០/I/១ ERN ០០២១២៣៣៤-៥២ (ភាសាអង់គ្លេស) និង ០០២០៧៤១១-២៩ (ភាសាបារាំង) ដីកាស្ដីពីសិទ្ធិបកប្រែ និងកាតព្វកិច្ចនៃបណ្ដាភាគី ច.ស.ក ថ្ងៃទី១៩ ខែមិថុនា ឆ្នាំ២០០៨ A១៩០ ERN ០០១៩៦២៣-៣០ (ភាសាអង់គ្លេស)។

មិនស្របច្បាប់ ឬមិនប្រក្រតីដែរ។ ដូច្នេះ ការអះអាងរបស់មេធាវីការពារក្ដីខាងក្រោម គ្មានអ្វីក្រៅតែពីជាការប៉ាន់ស្មានតែប៉ុណ្ណោះ៖

- "ដីកាសម្រេចអំពីការបន្តថិរវេលានៃការឃុំខ្លួនបណ្ដោះអាសន្ន ជាដីការសម្រេច ដោយមិនសម្អាងលើអង្គច្បាប់"[35]។
- "អវត្តមាននៃការបកប្រែឯកសារភស្តុតាង និងវិធានការណ៍នានា ដែលបានសម្រេច តាំងពីពេលនោះបានធ្វើឲ្យប៉ះពាល់សិទ្ធិខៀវ សំផន យ៉ាងខ្លាំងក្លា និងការរំលោភសិទ្ធិជនត្រូវចោទរូបនេះ គឺកំពុងមានជាប់ជាបន្ត"[36]។
- "គ្រប់វិធានការណ៍នីតិវិធីទាំងអស់ប្រឆាំងនឹង ខៀវ សំផន សុទ្ធតែមានខ្វះចន្លោះ ជាពិសេសនោះគឺដីកាសម្រេចឃុំខ្លួនបណ្ដោះអាសន្ន"[37]។

ដូច្នេះ ការស្នើពន្យាពេលការសម្រេចបន្តថិរវេលានៃការឃុំខ្លួនបណ្ដោះអាសន្ន គឺពឹងផ្អែកទាំងស្រុងទៅលើសេចក្ដីសម្រេចប៉ាន់ស្មានរបស់ អ.ប.ជ នាពេលនេះ មិនអាចបង្កើតតម្លៃគតិយុត្តិនៃច្បាប់ ឬធ្វើជាមូលដ្ឋានណាមួយសម្រាប់សហចៅក្រមស៊ើបអង្កេតសម្រេច មិនបន្តថិរវេលានៃការឃុំខ្លួនបណ្ដោះអាសន្នបាននោះទេ។

១៣. គ្មានវិធានផ្ទៃក្នុង ឬបញ្ញត្តិនៃក្រមនីតិវិធីព្រហ្មទណ្ឌណាមួយ ("ក្រមនីតិវិធីព្រហ្មទណ្ឌ") តម្រូវឲ្យសហចៅក្រមស៊ើបអង្កេតពន្យាពេលការសម្រេចរបស់ខ្លួន ដោយរង់ចាំរហូតទាល់តែអ.ប.ជ បានឈានដល់ការសម្រេច ក្នុងនីតិវិធីដោយឡែកមួយឡើយ។ ហើយបណ្ដឹងឧទ្ធរណ៍ទៅ អ.ប.ជពុំអាចផ្អាកកិច្ចដំណើរការនីតិវិធីណាមួយនោះទេ។ គោលការណ៍នេះត្រូវបានរំឭកឡើងវិញដោយសហចៅក្រមស៊ើបអង្កេត នៅក្នុងដីកាសម្រេចអំពីការបន្តថិរវេលានៃការឃុំខ្លួនបណ្ដោះអាសន្ន[38]។

---

[35] បណ្ដឹងឧទ្ធរណ៍ C២៦/៥/១ កថាខណ្ឌទី៥ ទី៣៣ ចំណងជើងនៅលើកថាខណ្ឌទី៥៣-៦២ កថាខណ្ឌទី៧៨។

[36] បណ្ដឹងឧទ្ធរណ៍ C២៦/៥/១ កថាខណ្ឌទី៣៣។

[37] បណ្ដឹងឧទ្ធរណ៍ C២៦/៥/១ កថាខណ្ឌទី៣៣។

[38] ដីកាបន្តថេរៈវេលា C២៦/៤ កថាខណ្ឌ ១៥-១៦

00273971



១៤. វិធាន ៦៣ (៤) និង(៧) នៃវិធានផ្ទៃក្នុងពុំបានចែងអំពីអនុភាពណាមួយនៃការព្យួរបណ្តឹងឧទ្ធរណ៍របស់ជនត្រូវចោទ ប្រឆាំងនឹងដីការបស់សហចៅក្រមស៊ើបអង្កេតឡើយ។ សហចៅក្រមស៊ើបអង្កេតពុំមានកាតព្វកិច្ចពន្យាពេលកិច្ចដំណើរការនីតិវិធីឡើយ។ អ្វីដែលផ្ទុយ ពីនេះនឹងតម្រូវឱ្យសហចៅក្រមស៊ើបអង្កេត ។ ការព្យួរការសម្រេចលើបណ្តឹងឧទ្ធរណ៍ណាដែលគាំទ្រមេធាវីការពារក្តី មិនអនុវត្តកិច្ចស៊ើបសួររបស់ខ្លួន ដែលការសន្មតបែបនេះចាត់ទុកថាមិនអាចយកជាការបាន។ វាមិនទាន់គ្រប់គ្រាន់ទេ ដោយគ្រាន់តែអះអាងពីភាពមិនប្រក្រតីនៃកិច្ចដំណើរការនីតិវិធីណាមួយនៅចំពោះអ.ប.ជ ដើម្បីរាំងសហចៅក្រមស៊ើបអង្កេតកុំឱ្យចាត់វិធានការណ៍ ដែលពួកគេជឿថាជាការចាំបាច់ក្នុងការបន្តកិច្ចស៊ើបសួរ (និងជាពិសេសការសម្រេចបន្តថេរៈវេលានៃការឃុំខ្លួនបណ្តោះអាសន្ន)។ ការរំលោភសិទ្ធិជនត្រូវចោទ ដែលគេបានលើកឡើងទាក់ទិននឹងបញ្ហាការបកប្រែឯកសារភស្តុតាង ដែលបានលើកឡើងគ្រប់ក្នុងការសន្និដ្ឋានរបស់មេធាវីការពារក្តី ចាប់តាំងពីខែមេសា ឆ្នាំ២០០៨ មកនោះ នៅតែស្រពិចស្រពិលមិនច្បាស់លាស់ និងសុទ្ធសឹងតែជាការប៉ាន់ស្មាន់សុទ្ធសាធ។ ទឡ្ហីករណ៍លើកឡើងដោយមេធាវីការពារក្តី នៅក្នុងការសន្និដ្ឋានទាំងនោះ មានន័យស្មើនឹងការពន្យាពេលការចាត់វិធានការណ៍ និងអាចស្មើនឹង "ការរំលោភនីតិវិធី"។

១៥. លើសពីនេះ ផលវិបាកនៃការពន្យាពេលការសម្រេចបន្តថិរវេលានៃការឃុំខ្លួនបណ្តោះអាសន្នអាចធ្វើឱ្យប៉ះពាល់ដល់កិច្ចស៊ើបសួរ ដោយសារតែការពន្យាពេលការសម្រេចអាចបណ្តាលឱ្យមានការដោះលែងជនត្រូវចោទ បើទោះបីជាការរកឃើញរបស់សហចៅក្រមស៊ើបអង្កេតថា ការដោះលែងនឹងនាំមកនូវហានិភ័យជាក់ស្តែងមួយដល់ជនរងគ្រោះ និងសាក្សី ការថែរក្សាភស្តុតាង សន្តិសុខផ្ទាល់ខ្លួននៃជនត្រូវចោទ និងសណ្តាប់ធ្នាប់សាធារណៈ ដែលទង្វើទាំងនោះអាចជៀសផុតពីការគោរពសេចក្តីសម្រេច ក្រោមវិធាន៦៣ (៣) (ក) និង (ខ)។

១៦. តាមរយៈស្មារតីនៃវិធានផ្ទៃក្នុង សហចៅក្រមស៊ើបអង្កេត ត្រូវបានផ្តល់អំណាចឱ្យសម្រេចអំពីការរក្សាទុកការឃុំខ្លួនបណ្តោះអាសន្ន ឬការបន្តថិរវេលានៃការឃុំខ្លួនបណ្តោះអាសន្ន។ សិទ្ធិអំណាចនេះ ត្រូវបានអនុវត្តក្នុងដែនកំណត់គ្រប់គ្រងមួយដោយអ.ប.ជ និងបន្ទាប់ពីមេធាវីការពារក្តីមានឱកាសស្វែងរកមធ្យោបាយតាមផ្លូវច្បាប់រួចមក។ ដូច្នេះសហចៅក្រមស៊ើបអង្កេតមិនអាចត្រូវបានចាប់ទោសកំហុស ចំពោះការប្រើប្រាស់សមត្ថកិច្ចណាមួយ ក្នុងចំណោម

00273972



សមត្ថកិច្ចទាំងឡាយ ដែលវិធានផ្ទៃក្នុងបានផ្ដល់ឱ្យនោះឡើយ។ ដូចដែលសហចៅក្រមស៊ើបអង្កេតបានបញ្ជាក់ នៅក្នុងដីកាសម្រេចអំពីការបន្តថិរវេលានៃការឃុំខ្លួនបណ្ដោះអាសន្នរួចហើយថា ដោយសារពួកគេត្រូវចេញដីកាសម្រេចដោះលែងជនត្រូវចោទ ប្រសិនបើលក្ខខណ្ឌនៃវិធាន ៦៣ មិនត្រូវបានបំពេញនោះ។ ពួកគេមានកាតព្វកិច្ចវិជ្ជមាន ក្នុងការវាយតម្លៃឡើងវិញ នូវលក្ខខណ្ឌសម្រាប់ការឃុំខ្លួនបន្ត នៅមុនថ្ងៃទី១៩ ខែវិច្ឆិកា ឆ្នាំ២០០៨ និងសម្រេច ថាតើត្រូវបន្តថិរវេលានៃការឃុំខ្លួនបណ្ដោះអាសន្ន ឬយ៉ាងណា[39]។

១៧. ក្នុងហេតុការណ៍ណាក៏ដោយ ប្រសិនបើអ.ប.ជ ពិចារណាអំពីការសម្រេចនៅពេលខាងមុខទាក់ទិននឹងសិទ្ធិបកប្រែឯកសារភស្តុតាង ឃើញថាសិទ្ធិរបស់ជនត្រូវចោទត្រូវបានរំលោភតាមមធ្យោបាយណាក្ដី សហចៅក្រមស៊ើបអង្កេតត្រូវតែអនុវត្តភ្លាមៗនូវសេចក្ដីសម្រេចណាមួយដើម្បីដោះលែងជនត្រូវចោទនោះ ។ ដែលការណ៍នេះគឺជាមធ្យោបាយតាមផ្លូវច្បាប់ដ៏សមស្របមួយ។ ក្នុងពេលជាមួយគ្នានេះ ដីការបស់សហចៅក្រមស៊ើបអង្កេត ចុះថ្ងៃទី១៩ ខែមិថុនា ថ្ងៃទី២៨ ខែតុលា និងថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ២០០៨[40] អាចអនុវត្តបានក្រោមវិធានផ្ទៃក្នុងទាល់តែដីកា ទាំងនោះត្រូវបាន អ.ប.ជ ពិចារណាឡើងវិញនៅក្នុងបណ្ដឹងឧទ្ធរណ៍រួចសិន។

### ខ. ម្ចាស់បណ្ដឹងឧទ្ធរណ៍មិនអាចចោទសួរអំពីភាពមិនលម្អៀងនៃសហចៅក្រមនៅក្នុងបណ្ដឹងឧទ្ធរណ៍នេះទេ

១៨. ជនត្រូវចោទបានលើកអំណះអំណាងថា សហចៅក្រមស៊ើបអង្កេតលម្អៀង ហើយដូច្នេះសេចក្ដីសម្រេចទាំងឡាយណាអំពីការបន្តថិរវេលានៃការឃុំខ្លួនគឺមិនស្របច្បាប់[41]។ ការចោទប្រកាន់នេះគ្មានទេ នៅក្នុងបណ្ដឹងឧទ្ធរណ៍បច្ចុប្បន្ន។ បញ្ហាជាគោលការណ៍នៅក្នុងការកំណត់ឱ្យមានបណ្ដឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេចអំពីការបន្តថិរវេលា នៃការឃុំខ្លួនបណ្ដោះអាសន្ន គឺថាតើលក្ខខណ្ឌដែលមានចែងក្នុងវិធាន ៦៣ (៣)នោះនៅតែត្រូវបានបំពេញដដែលឬយ៉ាងណា។

[39] ដីកាបន្តថេរ:វេលា C២៦/៤ កថាខណ្ឌ១៦។

[40] A១៩០ C៤០/៤ និង C២៦/៤។

[41] បណ្ដឹងឧទ្ធរណ៍ C២៦/៥/១ កថាខណ្ឌទី៤៧-៥២។

១៩. បន្ថែមពីលើនេះទៀត វិធានផ្ទៃក្នុងបានបើកផ្លូវឲ្យជនត្រូវចោទតវ៉ាចំពោះការកង្វះភាពមិនលម្អៀង របស់ស្ថាប័នតុលាការណាមួយនៃ អ.វ.ត.ក តាមរយៈការដាក់ពាក្យបណ្តឹងជិតចិត្ត ក្រោមវិធាន៣៤។ គេបានសន្និដ្ឋានថាសេចក្តីសម្អាងណាដែលបានលើកឡើងនៅក្នុងបណ្តឹងឧទ្ធរណ៍នៃមេធាវីការពារក្តី ទាក់ទងអំពីកង្វះភាពមិនលម្អៀង ឬអនាគតិដែលត្រូវបានចោទប្រកាន់មិនអាចត្រូវបាន អ.ប.ជ ពិចារណាឡើយ ព្រោះបញ្ហានោះហួសពីវិសាលភាពនៃបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេចអំពីការបន្តថិរវេលានៃការឃុំខ្លួនបណ្តោះអាសន្ន។

២០. ប្រសិនបើមេធាវីការពារក្តីជឿជាក់ថាខ្លួនមានមូលដ្ឋានអង្គច្បាប់ដែលធ្វើយុត្តិកម្មបណ្តឹងជិតចិត្តមួយចំពោះមន្ត្រីតុលាការមួយរូបណានៃអ.វ.ត.កនោះ ជនត្រូវចោទគួរធ្វើបណ្តឹងជិតចិត្ត ក្រោមវិធាន ៣៤[42]។

២១. ក្នុងករណីណាក៏ដោយ ការអះអាងថាសហចៅក្រមស៊ើបអង្កេតមានភាពលម្អៀង គឺមិនអាចទទួលយកបានឡើយឡើយ។ ជាចាំបាច់ មេធាវីការពារក្តីពុំអាចពឹងផ្អែកទាំងស្រុង ទៅលើសេចក្តីសម្រេចមុនៗ ដែលមានលក្ខណៈឯករាជ្យ ប៉ុន្តែមិនគួរជាទីចង់បាន របស់សហចៅក្រមស៊ើបអង្កេតស្តីពីបញ្ហាចោទនៃការបកប្រែឯកសារភស្តុតាង ដើម្បីសន្និដ្ឋានថាដីកាសម្រេចអំពីការបន្តថិរវេលានៃការឃុំខ្លួនបណ្តោះអាសន្ន មានភាពលម្អៀងនោះទេ។ គួររំឮកឡើងវិញថា សហចៅក្រមស៊ើបអង្កេតបានបំពេញតួនាទីរបស់ខ្លួនដោយឯករាជ្យ និងមិនលម្អៀង មិនគិតថាភាគីទាំងនោះដើរតួនាទីសកម្មអំឡុងកិច្ចស៊ើបសួរ ឬអត់នោះឡើយ។ សេចក្តីសម្រេចបន្តថិរវេលានៃការឃុំខ្លួនបណ្តោះអាសន្ន គឺឈរលើលក្ខណៈវិនិច្ឆ័យផ្លូវច្បាប់អង្គហេតុនៃវិធាន៦៣(៣)។ វាមិនសមហេតុសមផលឡើយក្នុងការលើកអំណះអំណាងថាសេចក្តីសម្រេចរបស់សហចៅក្រមស៊ើបអង្កេត ដើម្បីបន្តថិរវេលានៃការឃុំខ្លួនបណ្តោះអាសន្ននេះ គឺផ្ទាល់បណ្តាលមកពីសេចក្តីសម្រេចដោយឡែក ស្តីពីសិទ្ធិបកប្រែឯកសារភស្តុតាង។

---

[42] មកទល់ពេលនេះ សហមេធាវីអន្តរជាតិរូបនេះ បានតវ៉ាអំពីភាពស្របច្បាប់ និងភាពមិនលម្អៀងរបស់អ.វ.ត.ក ក្នុងប្រព័ន្ធផ្សព្វផ្សាយ ""Jacques Vergès មេធាវី ខៀវ សំផន និងជាមិត្ត ប៉ុល ពត: "គ្មានទេអ្វីដែលជាបិសាចផ្តាច់ការនោះ" Der Spiegel ចុះថ្ងៃទី២២ ខែវិច្ឆិកា ឆ្នាំ២០០៨។ ឧបសម្ព័ន្ធ ខ - ឯកសារភ្ជាប់ លេខ ១។

សេចក្តីសម្រេចស្តីពីសិទ្ធិបកប្រែឯកសារភស្តុតាង មិនជាប់ពាក់ព័ន្ធផ្ទាល់ទៅនឹង នីត្យានុកូលភាព នៃការឃុំខ្លួនបណ្តោះអាសន្នទេ ដូចដែលអ.ប.ជ បានកំណត់រួចមកហើយ[43]។

២២. មេធាវីការពារក្តីបានលើកអំណះអំណាងថែមទៀតថា ដីកាសម្រេចអំពីការបន្តថិរវេលានៃការឃុំខ្លួនបណ្តោះអាសន្នគឺទុកជាមោឃៈ និងគួរត្រូវបានចាត់ទុកថា"ស្មុគ្រស្មាញ" ដោយសារតែមកពីមានសេចក្តីណែនាំមិនទាន់ពេលមួយរបស់អ.ប.ជជូនទៅមេធាវីការពារក្តី កាលពីថ្ងៃទី០២ ខែតុលា ឆ្នាំ២០០៨[44]។ សេចក្តីសម្អាងនេះគ្មានអង្គសេចក្តី ព្រោះបណ្តាលមកពីមូលហេតុពីរ៖ (១)មេធាវីការពារក្តីបានដកបណ្តឹងឧទ្ធរណ៍របស់ខ្លួនប្រឆាំងនឹងដីកាសម្រេចអំពីការបន្តថិរវេលានៃការឃុំខ្លួនបណ្តោះអាសន្នដោយស្ម័គ្រចិត្ត ដូច្នេះហើយទើបខកខានមិនបានដាក់ការសន្និដ្ឋានណាមួយទៅកាន់ អ.ប.ជ ថាមានការរំលោភណាមួយទៅលើសិទ្ធិ ជនត្រូវចោទ (២) មាត្រា ២៧៨ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ដែលជាចំណុចសំខាន់នៃសេចក្តីសម្អាងរបស់មេធាវីការពារក្តី មិនអាចយកមកអនុវត្តនៅចំពោះមុខ អ.វ.ត.ក បានឡើយ។

**គ. បណ្តឹងឧទ្ធរណ៍មិនបានបង្ហាញអំពីការប្រែប្រួលស្ថានភាពអង្គហេតុដើម្បីធ្វើឱ្យមានយុត្តិកម្មក្នុងការលើកយកបញ្ហាឃុំខ្លួនបណ្តោះអាសន្នមកពិចារណាឡើងវិញទេ**

២៣. វិធាន៦៣(៦) និង(៧) បានចែងអំពីការពិនិត្យឡើងវិញតាមពេលវេលាទៀងទាត់ជាស្វ័យប្រវត្តិលើការឃុំខ្លួនបណ្តោះអាសន្នជនត្រូវចោទ។ បទប្បញ្ញត្តិបែបនេះមិនមានចែងនៅក្នុងឯកសារមូលដ្ឋានរបស់តុលាការឧក្រិដ្ឋកម្មអន្តរជាតិ សម្រាប់អតីតប្រទេសយូហ្គោស្លាវី ("តុលាការICTY") និងរ៉្វាន់ដា ("តុលាការICTR") និងតុលាការពិសេសសម្រាប់ប្រទេសសេរ៉ាឡេអូន

---

[43] សំណុំរឿង ខៀវ សំផន សេចក្តីណែនាំរបស់អ.ប.ជ ស្តីពីការបន្តកិច្ចដំណើរការនីតិវិធី ទាក់ទិននឹងបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងការឃុំខ្លួនបណ្តោះអាសន្ន ចុះថ្ងៃទី១២ ខែតុលា ឆ្នាំ២០០៨ C២៦/I/២៧ ERN ០០២១២៣៥៣-៥៥ (ភាសាអង់គ្លេស) កថាខណ្ឌទី៧-១០។

[44] បណ្តឹងឧទ្ធរណ៍ C២៦/៥/១ កថាខណ្ឌទី៧៥ និងទី៧១-៧៤ សំណុំរឿង ខៀវ សំផន សេចក្តីណែនាំរបស់អ.ប.ជ ស្តីពីការបន្តកិច្ចដំណើរការនីតិវិធី ទាក់ទងនឹងបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងការឃុំខ្លួនបណ្តោះអាសន្ន ចុះថ្ងៃទី១២ ខែតុលា ឆ្នាំ២០០៨ C២៦/I/២៧ ERN០០២១២៣៥៣-៥៥ (ភាសាអង់គ្លេស)។

("តុលាការSCSL")ទេ។ ប៉ុន្តែ តុលាការពិសេសទាំងនេះបានកំណត់ថា ដើម្បីអាចដាក់ពាក្យបណ្តឹងសារជាថ្មី ស្នើសុំឱ្យដោះលែងនៅក្រៅឃុំជាបណ្តោះអាសន្នបាន ចុងចោទត្រូវតែបង្ហាញអំពី "ការប្រែប្រួលស្ថានភាពអង្គហេតុ"[45]។

២៤. ស្របជៀងគ្នានឹងវិធានផ្ទៃក្នុងនៃតុលាការនេះ វិធាន១១៨ នៃវិធានភស្តុតាងនិងនីតិវិធីរបស់តុលាការព្រហ្មទណ្ឌអន្តរជាតិ ("តុលាការICC") តម្រូវថា អង្គបុរេជំនុំជម្រះត្រូវសើរើពិនិត្យការឃុំខ្លួនចុងចោទមុនពេលជំនុំជម្រះ ឡើងវិញយ៉ាងតិចណាស់ជារៀងរាល់១២០ថ្ងៃម្តង។ អង្គបុរេជំនុំជម្រះរបស់តុលាការICC មាន"កាតព្វកិច្ចឯករាជ្យនិងពិសេស [...] ដើម្បីធានាថាបុគ្គលនោះមិនត្រូវបានគេឃុំឃាំងក្នុងរយៈពេលមិនសមរម្យមុនពេលជំនុំជម្រះទេ"[46]។ អង្គបុរេជំនុំជម្រះអាចកែប្រែសេចក្តីសម្រេចរបស់ខ្លួនចំពោះការឃុំខ្លួនបណ្តោះអាសន្ន "ប្រសិនអង្គបុរេជំនុំជម្រះយល់ឃើញថា ការផ្លាស់ប្តូរស្ថានភាពអង្គហេតុ តម្រូវឱ្យធ្វើដូច្នេះ"[47]។ នៅតុលាការICC "រដ្ឋអាជ្ញាមានបន្ទុកដាក់ភស្តុតាងទាក់ទងនឹងការបន្តឱ្យមានការឃុំខ្លួន [...] មុនការជំនុំជម្រះ[48]"។

---

[45] *រឿងក្តីរដ្ឋអាជ្ញា តទល់នឹង Boskoski និង Tarculovski* សំណុំរឿងលេខ IT-04-82-PT សេចក្តីសម្រេចទាក់ទងនឹងការដាក់បណ្តឹងជាថ្មីស្នើសុំឱ្យដោះលែងJohan Tarculovski ជាបណ្តោះអាសន្ន កាលពីថ្ងៃទី១៧ ខែមករា ឆ្នាំ២០០៧ កថាខណ្ឌទី៩។

[46] ស្ថានភាពនៅសាធារណរដ្ឋប្រជាធិបតេយ្យកុងហ្គោ នៅក្នុង*រឿងក្តីរដ្ឋអាជ្ញា តទល់នឹង Germaine Katanga និង Mathieu Ngudjolo Chui* សេចក្តីសម្រេចទាក់ទងនឹងការអង្កេតស្តីពីការពិនិត្យឡើងវិញចំពោះការឃុំខ្លួនGermaine Katangaមុនពេលជំនុំជម្រះ សំណុំរឿងលេខ ICC-01/04-01/07 អង្គបុរេជំនុំជម្រះ កាលពីថ្ងៃទី៩ ខែកក្កដា ឆ្នាំ២០០៨ ទំព័រទី៤។

[47] ស្ថានភាពនៅសាធារណរដ្ឋប្រជាធិបតេយ្យកុងហ្គោ នៅក្នុង*រឿងក្តីរដ្ឋអាជ្ញា តទល់នឹង Germaine Katanga និង Mathieu Ngudjolo Chui* ការពិនិត្យឡើងវិញនូវសេចក្តីសម្រេចស្តីពីលក្ខខណ្ឌនៃការឃុំខ្លួនGermaine Katanga មុនពេលជំនុំជម្រះ សំណុំរឿងលេខ ICC-01/04-01/07 អង្គបុរេជំនុំជម្រះ កាលពីថ្ងៃទី១៨ ខែសីហា ឆ្នាំ២០០៨ ទំព័រទី៦។

[48] ស្ថានភាពនៅសាធារណរដ្ឋប្រជាធិបតេយ្យកុងហ្គោ នៅក្នុង*រឿងក្តីរដ្ឋអាជ្ញា តទល់នឹង Germaine Katanga និង Mathieu Ngudjolo Chui* សេចក្តីសម្រេចទាក់ទងនឹងការអង្កេតស្តីពីការពិនិត្យឡើងវិញចំពោះការឃុំខ្លួនGermaine Katangaមុនពេលជំនុំជម្រះ សំណុំរឿងលេខ ICC-01/04-01/07 អង្គបុរេជំនុំជម្រះ កាលពីថ្ងៃទី៩ ខែកក្កដា ឆ្នាំ២០០៨ ទំព័រ៤។

២៥. ចំពោះមុខតុលាការនេះ នៅពេលសហចៅក្រមស៊ើបអង្កេតចេញដីកាបន្តថេរៈវេលានៃការឃុំខ្លួនបណ្ដោះអាសន្ន វិធានផ្ទៃក្នុងមិនតម្រូវឱ្យសហចៅក្រមស៊ើបអង្កេតស្ដាប់អំណះអំណាងរបស់សហព្រះរាជអាជ្ញា ឬភាគីផ្សេងទៀតណាមួយនោះទេ ក្រៅតែពីជនត្រូវចោទ។ ភាគីទាំងនោះអាចដាក់ការជំទាស់របស់ខ្លួនបាន ដែលការជំទាស់នឹងត្រូវដាក់ដោយជនត្រូវចោទ។ អត្ថិភាពនៃការពិនិត្យជាស្វ័យប្រវត្តិចំពោះការបន្តថិរវេលានៃការឃុំខ្លួនបណ្ដោះអាសន្ន ផ្ដល់ឱកាសជាច្រើនដល់ជនជាប់ឃុំ ដើម្បីបង្ហាញគោលជំហររបស់គាត់ ឬអនុវត្តសិទ្ធិរបស់ខ្លួន តាមរយៈការប្ដឹងឧទ្ធរណ៍ប្រឆាំងនឹងសេចក្ដីសម្រេច ដែលមានសម្អាង ហេតុផល[49]។

២៦. ម្ចាស់បណ្ដឹងឧទ្ធរណ៍ មិនបានបញ្ជាក់អំពីការប្រែប្រួលស្ថានភាពអង្គហេតុណាមួយ ដែលជាការចាំបាច់ ឱ្យមានការពិចារណាឡើងវិញចំពោះការឃុំខ្លួនបណ្ដោះអាសន្នលើរូបគាត់ ឬការផ្លាស់ប្ដូរលក្ខខណ្ឌនៃការឃុំខ្លួនទេ។ ផ្ទុយទៅវិញ សហមេធាវីការពារក្ដីបានផ្អែកលើទឡ្ហីករណ៍ដែលទាក់ទងតែភាសា ដោយគ្រាន់តែលើកឡើងថា សេចក្ដីសម្រេចបន្តថិរវេលានៃការឃុំខ្លួនបណ្ដោះអាសន្នធ្វើឡើងតាមអំពើចិត្ត និងសេចក្ដីសម្រេចបែបនេះមិនចាំបាច់មាននោះទេ។ ប៉ុន្តែ បណ្ដឹងឧទ្ធរណ៍មិនបានលើកឡើងអំពីអង្គហេតុដើម្បីគាំទ្រអំណះអំណាងទាំងនេះទេ។ កាលពីថ្ងៃទី២៨ ខែតុលា ឆ្នាំ២០០៨ សហចៅក្រមស៊ើបអង្កេតបដិសេធសំណើរបស់ជនត្រូវចោទស្នើសុំឱ្យដោះលែង នៅក្រៅឃុំជាបណ្ដោះអាសន្ន ពីព្រោះលក្ខខណ្ឌនៃវិធាន៦៣(៣) ត្រូវបានបំពេញ និងថិរវេលានៃការឃុំខ្លួនជនត្រូវចោទមិនទាន់លើសពីការកំណត់របស់ច្បាប់ទេ[50]។ ពិតណាស់ ចាប់តាំងពីពេលចេញដីកាឃុំខ្លួនបណ្ដោះអាសន្នលើកដំបូង កាលពីខែវិច្ឆិកា ឆ្នាំ២០០៧ សហមេធាវីការពារក្ដីមិនបានដាក់ភស្ដុតាងណាមួយក្រោយពេលចេញសេចក្ដីសម្រេច ដើម្បីបង្ហាញនូវការប្រែប្រួលស្ថានភាពអង្គហេតុ ដើម្បីធ្វើឱ្យមានយុត្តិកម្មក្នុងការលើកយកសេចក្ដីសម្រេចដែលចេញដោយសហចៅក្រមស៊ើបអង្កេតនោះ មកពិចារណាឡើងវិញនោះទេ។

---

[49] វិធាន៦៣(៧) នៃវិធានផ្ទៃក្នុង។

[50] ដីកាបដិសេធសំណើសុំដោះលែងឱ្យមានសេរីភាព C40/4។

២៧. សហមេធាវីការពារក្ដី បានចង្អុលបង្ហាញនូវចំណុច "ការផុតកំណត់នៃរយៈពេលឃុំខ្លួនស្របច្បាប់" ជា "ការប្រែប្រួលមួយ" ដែលត្រូវតែ "លើកយកមកពិចារណា"[51]។ ប៉ុន្តែ ១) ការឃុំខ្លួនបណ្ដោះអាសន្ន នៅតែស្របច្បាប់ដោយយោងតាមវិធាន ៦៣(៦)[52] និង ២) សហចៅក្រមស៊ើបអង្កេតបានពិចារណាលើថេរវេលា នៃការឃុំខ្លួនបណ្ដោះអាសន្នក្នុងការចេញសេចក្ដីសម្រេចរបស់ខ្លួន[53]។ នៅពេលដែលថិរវេលាក្នុងការឃុំខ្លួនបណ្ដោះអាសន្នត្រូវបានតុលាការអន្តរជាតិនានាចាត់ទុកថាជាកត្តាពាក់ព័ន្ធមួយ ក្នុងការកំណត់អំពីភាពស្របច្បាប់នៃការឃុំឃាំងខ្លួន[54] សហមេធាវីការពារក្ដីមិនបានបង្ហាញថា ការឃុំខ្លួនរយៈពេលមួយឆ្នាំធ្វើឱ្យខូចប្រយោជន៍ដល់រឿងក្ដីរបស់ដើមបណ្ដឹងឧទ្ធរណ៍ ក្នុងលក្ខណៈដែលធ្វើឱ្យអាក់ខានដល់ការជំនុំជម្រះដោយយុត្តិធម៌ និង/ឬ បង្ហាញថាករណីធ្វើឱ្យខូចប្រយោជន៍នេះ អាចមានយុត្តិកម្មដើម្បីការឃុំខ្លួនជាបណ្ដោះអាសន្នមកធ្វើឱ្យពិចារណាឡើងវិញនោះទេ [55]។

២៨. សហព្រះរាជអាជ្ញា ត្រូវតែលើកទឡ្ហីករណ៍នានា ដែលធ្វើឱ្យការឃុំខ្លួនមានយុត្តិកម្ម។ លក្ខខណ្ឌចំនួនពីរ ដែលមានចែងនៅក្នុងវិធាន៦៣(៣) នូវតែត្រូវបានបំពេញ និងមានយុត្តិកម្មចំពោះការបន្តថិរវេលានៃការឃុំខ្លួនបណ្ដោះអាសន្នចំនួនមួយឆ្នាំបន្ថែមទៀត។

---

[51] បណ្ដឹងឧទ្ធរណ៍ C26/5/1 កថាខណ្ឌទី៥៩។

[52] វិធាន៦៣(៦) នៃវិធានផ្ទៃក្នុង។

[53] ដីកាបន្តថេរៈវេលា C26/4 កថាខណ្ឌទី២៩។ ដីកាបដិសេធសំណើសុំដោះលែងឱ្យមានសេរីភាព C40/4 កថាខណ្ឌទី២៦ ដល់ទី៣០។

[54] *រឿងក្ដី រដ្ឋអាជ្ញា តទល់នឹង* Tihomir Blaskic ដីកាបដិសេធបណ្ដឹងស្នើសុំឱ្យដោះលែងបណ្ដោះអាសន្ន សំណុំរឿងលេខ IT-94-14-អង្គជំនុំជម្រះសាលាដំបូង កាលពីថ្ងៃទី២០ ធ្នូ ឆ្នាំ១៩៩៦៖ តុលាការICTY បានបង្កើតនៅក្នុងសេចក្ដីសម្រេចនោះថា ដើម្បីអាចបង្កើតថេរៈវេលានៃការឃុំខ្លួនបណ្ដោះអាសន្នឱ្យមានលក្ខណៈសមហេតុផល យើងចាំបាច់ត្រូវវាយតម្លៃស្ថានភាពនៃរឿងក្ដីនីមួយដោយផ្អែកលើលក្ខខណ្ឌវិនិច្ឆ័យដូចខាងក្រោម៖ (ក) ថេរៈវេលាប្រសិទ្ធិភាពនៃការឃុំខ្លួន (ខ) ថេរៈវេលានៃការឃុំខ្លួនតាមប្រភេទនៃបទល្មើស (គ) ផលវិបាកផ្នែករូបរាងកាយ និងស្មារតីនៃការឃុំខ្លួនលើជនជាប់ឃុំ (ឃ) ភាពស្មុគស្មាញនៃរឿងក្ដីនិងការស៊ើបអង្កេត (ង) ការប្រតិបត្តិដំណើរការនីតិវិធីទាំងមូល។ ស្ថានភាពនៅសាធារណរដ្ឋប្រជាធិបតេយ្យកុងហ្គោ នៅក្នុង*រឿងក្ដីរដ្ឋអាជ្ញា តទល់នឹង Germaine Katanga និង Mathieu Ngudjolo Chui* ការពិនិត្យឡើងវិញចំពោះសេចក្ដីសម្រេចលើបណ្ដឹងសុំឱ្យដោះលែងMathieu Ngudjolo Chuiបណ្ដោះអាសន្ន សំណុំរឿងលេខ 01/04-01/07 អង្គបុរេជំនុំជម្រះរបស់តុលាការICC កាលពីថ្ងៃទី២៣ ខែកក្កដា ឆ្នាំ២០០៨ ទំព័រ១២។

[55] បណ្ដឹងឧទ្ធរណ៍ C26/5/1 កថាខណ្ឌទី៥៩។

## ឃ. វិធាន ៦៣(៣)៖ មានមូលហេតុដែលត្រូវបានរកឃើញ និងជឿជាក់យ៉ាងច្បាស់ថា ដើមបណ្តឹងឧទ្ធរណ៍ធ្លាប់បានប្រព្រឹត្តបទល្មើសដែលបានចោទប្រកាន់

២៩. នៅដំណាក់កាលនេះនៃការស៊ើបអង្កេត សំណុំរឿងសព្វថ្ងៃបានបង្ហាញភស្តុតាងដែលអាចធ្វើឱ្យអ្នកសង្កេតការដោយមិនលម្អៀងជឿថា ដើមបណ្តឹងឧទ្ធរណ៍ធ្លាប់បានប្រព្រឹត្តបទល្មើសដែលគេកំពុងស៊ើបអង្កេត។ ការលើកឡើងនេះត្រូវបានអង្គបុរេជំនុំជម្រះបញ្ជាក់យ៉ាងច្បាស់លាស់[56]។

៣០. នៅក្នុងបណ្តឹងឧទ្ធរណ៍ សហមេធាវីការពារក្តីមិនបានដាក់ទឡ្ហីករណ៍ពាក់ព័ន្ធណាមួយ ដោយផ្អែកតាមវិធាន៦៣(៣)(ក)។ ជាការពិតណាស់ សហមេធាវីការពារក្តីមិនបានប្រឆាំងនឹងអត្ថិភាពនៃមូលហេតុដែលត្រូវបានរកឃើញ និងជឿជាក់យ៉ាងច្បាស់ថា ជនត្រូវចោទធ្លាប់បានប្រព្រឹត្តបទល្មើសដែលមានចែងនៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ។

៣១. ដូច្នេះ សហព្រះរាជអាជ្ញាយល់ថា វាចាំបាច់គ្រាន់តែលើកឡើងអំពីធាតុថ្មីៗមួយចំនួន តាមវិធាន៦៣(៣) (ក) ដែលវិធាននេះមានការជាប់ពាក់ព័ន្ធចាប់តាំងពីពេលចាប់ខ្លួនដើមបណ្តឹងឧទ្ធរណ៍។ ដោយសារតែមានភស្តុតាងដាក់គាំទ្រដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ ដែលជាចំណុចគ្រប់គ្រាន់ក្នុងការបញ្ជាក់អំពីលក្ខខណ្ឌត្រឹមត្រូវតាមច្បាប់នៃ "មូលហេតុដែលត្រូវបានរកឃើញនិងជឿជាក់" សហព្រះរាជអាជ្ញាបានបញ្ចូលចំណុចនេះជាអំណះអំណាងសម្អាងដែលមានចែងនៅក្នុងកថាខណ្ឌទី២៤-២៦ និងកថាខណ្ឌទី៣៣-៥២ នៃ"ចម្លើយតបរបស់សហព្រះរាជអាជ្ញាទៅនឹងបណ្តឹងឧទ្ធរណ៍របស់ ខៀវ សំផន ប្រឆាំងនឹងដីកាឃុំខ្លួនបណ្តោះ

[56] សាលដីការបស់អង្គបុរេជំនុំជម្រះលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាឃុំខ្លួនបណ្តោះអាសន្ន នួន ជា ចុះថ្ងៃទី២០ ខែមីនា ឆ្នាំ២០០៨ C11/54, ERN 00172907-34 កថាខណ្ឌទី៤៦។ សាលដីការបស់អង្គបុរេជំនុំជម្រះលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាឃុំខ្លួនបណ្តោះអាសន្ន អៀង ធីរិទ្ធ ចុះថ្ងៃទី៩ ខែកក្កដា ឆ្នាំ២០០៨ C22/I/27, ERN 00201633-49 កថាខណ្ឌទី២១។ សាលដីកាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាឃុំខ្លួនបណ្តោះអាសន្ន អៀង សារី C2/I/73 កថាខណ្ឌទី៧១។

អាសន្ននៅថ្ងៃទី១៩ ខែវិច្ឆិកា ឆ្នាំ២០០៧"[57]។ ចំណុះទាំងនេះក៏ត្រូវបានលើកឡើងនៅក្នុងដីការបស់សហចៅក្រមស៊ើបអង្កេត សម្រេចបដិសេធសំណើសុំដោះលែងឲ្យមានសេរីភាព ចុះថ្ងៃទី២៨ ខែតុលា ឆ្នាំ២០០៨ កថាខណ្ឌទី៧-១១[58]។

៣២. កាលពីថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ២០០៨ នៅក្នុងដីកាបន្តថេរៈវេលាដែលត្រូវបានគេប្តឹងជំទាស់ សហចៅក្រមស៊ើបអង្កេតបានយល់ឃើញថា មូលហេតុដែលត្រូវបានរកឃើញ បន្តធ្វើឲ្យមានការជឿជាក់ថា ម្ចាស់បណ្តឹងឧទ្ធរណ៍ធ្លាប់បានប្រព្រឹត្តបទល្មើស ដូចមានចែងក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរ។ សហចៅក្រមស៊ើបអង្កេតបានយល់ឃើញថា ការស៊ើបអង្កេតរបស់តុលាការមានភាពជឿនលឿន ចាប់តាំងពីពេលចាប់ខ្លួនជនត្រូវចោទ ដោយសារតែឯកសារភស្តុតាងបន្ថែមត្រូវបានប្រមូល និងបានពិចារណាលើរយៈពេលនៃការស៊ើបអង្កេតផងដែរ[59]។

៣៣. សហព្រះរាជអាជ្ញាបានលើកឡើងថា អង្គបុរេជំនុំជម្រះគួរតែបញ្ជាក់អំពីការរកឃើញពីមុនរបស់ខ្លួន ទាក់ទងនឹងអត្ថិភាព នៃមូលហេតុដែលត្រូវបានរកឃើញ និងជឿជាក់យ៉ាងច្បាស់ថា ជនត្រូវចោទធ្លាប់បានប្រព្រឹត្តបទល្មើសដែលត្រូវបានចោទប្រកាន់[60]។ តាមការពិនិត្យសំណុំរឿងបង្ហាញច្បាស់ថា មូលដ្ឋាននៃការជឿជាក់នេះមានសភាពខ្លាំងជាងមួយឆ្នាំមុន ដោយសារតែភស្តុតាងដែលដាក់បន្ទុកលើម្ចាស់បណ្តឹងឧទ្ធរណ៍មានកាន់តែច្រើនឡើង ទាំងចំនួន និងស្ថានទម្ងន់នៅប៉ុន្មានខែថ្មីៗនេះ។ សហចៅក្រមស៊ើបអង្កេតបានចេញយ៉ាងតិចណាស់ ដីកាចាត់ឲ្យ

---

[57] *រឿងក្តី ខៀវ សំផន* ចម្លើយតបរបស់សហព្រះរាជអាជ្ញាចំពោះបណ្តឹងឧទ្ធរណ៍របស់ ខៀវ សំផន ប្រឆាំងនឹងដីកាឃុំខ្លួនបណ្តោះអាសន្ន នៅថ្ងៃទី១៩ ខែវិច្ឆិកា ឆ្នាំ២០០៧ ចុះថ្ងៃទី៦ ខែកុម្ភៈ ឆ្នាំ២០០៨ C 26/I/9, ERN 00160767-95 (ភាសាអង់គ្លេស)។

[58] ដីកាបដិសេធសំណើសុំដោះលែងឲ្យមានសេរីភាព C40/4។

[59] ដីកាបន្តថេរៈវេលា C 26/4 កថាខណ្ឌទី២៥ សំដៅចំពោះកថាខណ្ឌទី៧ ដល់ទី១១ នៃដីការបស់សហចៅក្រមស៊ើបអង្កេតបដិសេធសំណើសុំឲ្យដោះលែងឲ្យមានសេរីភាព C40/4។

[60] នៅក្នុងសាលដីការបស់ខ្លួនលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាឃុំខ្លួនបណ្តោះអាសន្ន អៀង សារី អង្គបុរេជំនុំជម្រះយល់ឃើញថា ពាក្យ "ធ្លាប់បានប្រព្រឹត្ត" ត្រូវតែចាត់ទុកជា "ការបណ្តាលឲ្យមានការទទួលខុសត្រូវជាបុគ្គល" ចំពោះការរៀបចំ ញុះញង់ បញ្ជា ជួយនិងបង្កលក្ខណៈងាយស្រួល ឬប្រព្រឹត្ត និងការទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌរបស់ថ្នាក់លើ៖ សាលដីកាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាឃុំខ្លួនបណ្តោះអាសន្ន អៀង សារី C 22/I/74 កថាខណ្ឌទី៧១។

ស៊ើបសួរជំនួសចំនួនដប់បី នៅក្នុងសំណុំរឿងលេខ ០០២ (ឯកសារលេខ D25, D40, D43, D78, D82, D91, D92, D93, D94, D104, D107, D115, D123)[61] និងសហចៅក្រមស៊ើបអង្កេត ឬអ្នកស៊ើបអង្កេតរបស់ពួកគេ បានធ្វើការស្តាប់យកចម្លើយពីសាក្សីចំនួនជាងមួយរយនាក់ ទាក់ទងនឹងបទល្មើសជាច្រើនដែលជនទាំងប្រាំនាក់ រួមមានម្ចាស់បណ្តឹងឧទ្ធរណ៍ផង ត្រូវបានគេចោទប្រកាន់នៅក្នុងសំណុំរឿង ថាធ្លាប់បានប្រព្រឹត្ត[62]។ បន្ថែមពីលើនេះ ខ្លឹមសារសំខាន់នៅក្នុងសំណុំរឿងលេខ០០១ ដែលពាក់ព័ន្ធភាគច្រើននឹងរឿងក្តីម្ចាស់បណ្តឹងឧទ្ធរណ៍ ត្រូវបានគេដាក់បញ្ចូលក្នុងសំណុំរឿងលេខ០០២ ដោយមានចំណាររបស់សហចៅក្រមស៊ើបអង្កេតចុះថ្ងៃទី២៨ ខែតុលា ឆ្នាំ២០០៨[63]។ កំណត់ហេតុសួរចម្លើយ កាំង ហ្កេកអ៊ាវ ហៅ ឌុច ចំនួន២៨ ដែលធ្វើឡើងនៅក្នុងបរិបទសំណុំរឿងលេខ០០១ ត្រូវបានដាក់បញ្ចូលក្នុងសំណុំរឿងលេខ០០២ ដោយសហចៅក្រមស៊ើបអង្កេតកាលពីថ្ងៃទី៣០ ខែឧសភា ឆ្នាំ២០០៨[64]។ លើសពីនេះ (បានលុបចេញ)[65] [66]។

---

[61] ក្នុងចំណោមដីកាចាត់ឱ្យស៊ើបសួរជំនួស ដីកាចំនួនប្រាំបីទាក់ទងនឹងការស្តាប់យកចម្លើយសាក្សី៖ D 25 (ការស្តាប់យកចម្លើយសាក្សីមានចំនួន៣៦), D 40 (ការស្តាប់យកចម្លើយសាក្សីមានចំនួន២៥), D 91 (ការស្តាប់យកចម្លើយសាក្សីមានចំនួន២៤), D 92 (ការស្តាប់យកចម្លើយសាក្សីមានចំនួន៨), D 94 (ការស្តាប់យកចម្លើយសាក្សីមានចំនួន១៦), D 107 (យ៉ាងតិចណាសការស្តាប់យកចម្លើយសាក្សីមានចំនួនមួយ), D 115 (បានលុបចេញ) និង D123 (ការស្តាប់យកចម្លើយសាក្សីមានចំនួន៣) ជាសរុបមានយ៉ាងតិចណាស់ការស្តាប់យកចម្លើយសាក្សីមានចំនួន១១៨ ដែលបានដាក់នៅក្នុងសំណុំរឿង។ យោងតាមសហចៅក្រមស៊ើបអង្កេត ដីកាចាត់ឱ្យស៊ើបសួរជំនួសជាច្រើនកំពុងត្រូវបានគេអនុវត្ត។ វាមិនប្លែកទេក្នុងករណីដែលភាគីត្រូវបានជូនដំណឹងអំពីអត្ថិភាពនៃដីកាចាត់ឱ្យស៊ើបសួរជំនួសនៅពេលភាគីទាំងនោះបានបញ្ចប់វាសព្វគ្រប់។ វាមានន័យថា តាមការជាក់ស្តែង វាទំនងយ៉ាងខ្លាំងដែលថា ក.ស.ស បានប្រមូលចម្លើយសាក្សីច្រើនថែមទៀត ចាប់ពីពេលដាក់ចម្លើយសាក្សីចំនួន១១៥នៅក្នុងសំណុំរឿងរួចមក។ សហព្រះរាជអាជ្ញាជម្រុញឱ្យដាក់ចម្លើយសាក្សីឱ្យបានឆាប់រហ័សនៅក្នុងសំណុំរឿង មុនពេលរបាយការណ៍របស់ដីកាចាត់ឱ្យស៊ើបសួរជំនួសត្រូវបានបំពេញចប់សព្វគ្រប់។

[62] បច្ចុប្បន្ននេះ ដីកាបញ្ជូនរឿងទៅជំនុំជម្រះបានចេញនៅក្នុងសំណុំរឿងលេខ១ ដូច្នេះយើងសង្ឃឹមថា ល្បឿននៃការស៊ើបអង្កេតនឹងត្រូវបង្កើនឱ្យកាន់តែលឿននាពេលអនាគត។

[63] *រឿងក្តី នួន ជា និងអ្នកផ្សេងៗទៀត* មានចំណាររបស់សហចៅក្រមស៊ើបអង្កេត ចុះថ្ងៃទី២៨ ខែតុលា ឆ្នាំ២០០៨ D 108, ERN 00236076-77 (ភាសាអង់គ្លេស) និងឧបសម្ព័ន្ធ D 108/1។

[64] *រឿងក្តី នួន ជា និងអ្នកផ្សេងៗទៀត* មានចំណាររបស់សហចៅក្រមស៊ើបអង្កេត ចុះថ្ងៃទី៣០ ខែឧសភា ឆ្នាំ២០០៨ D 86, ERN 00194661-67 (ភាសាអង់គ្លេស)។

00273981

C26/5/10



៣៤. សហព្រះរាជអាជ្ញាបានចូលរួមក្នុងកិច្ចស៊ើបអង្កេត ដោយបានដាក់នូវឯកសារភស្តុតាងជាច្រើន នៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរ និងតាំងពីពេលចាប់ខ្លួនម្ចាស់បណ្តឹងឧទ្ធរណ៍[67]។ យើងគួររំឭកដែរថា ភស្តុតាងដែលសហចៅក្រមស៊ើបអង្កេតដាក់នៅក្នុងសំណុំរឿងតាមការស្នើសុំរបស់សហព្រះរាជអាជ្ញា (ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរ និងការដាក់ឯកសារបន្តបន្ទាប់នានា) ព្រមទាំងភស្តុតាងដែលសហចៅក្រមស៊ើបអង្កេតប្រមូលបានកាលពីឆ្នាំមុន បានបង្ហាញអំពីទម្រង់ និងប្រភេទទាំងអស់ នៃការចូលរួមរបស់ម្ចាស់បណ្តឹងឧទ្ធរណ៍ទៅនឹងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ និងឧក្រិដ្ឋកម្មសង្គ្រាមដែលគាត់ត្រូវបានគេចោទប្រកាន់ ដែលរួមមានឧក្រិដ្ឋកម្មផ្អែកលើភស្តុតាង ភស្តុតាងទាក់ទងនឹងឧក្រិដ្ឋកម្មដោយផ្អែកតាមរចនាសម្ព័ន្ធដឹកនាំ ដែលក្នុងនោះម្ចាស់បណ្តឹងឧទ្ធរណ៍បានអនុវត្តអំណាចបញ្ជា ភស្តុតាងដែលបង្ហាញអំពីការចូលរួមប្រព្រឹត្តរបស់គាត់នៅក្នុងសហកម្មឧក្រិដ្ឋកម្មរួម និងភស្តុតាងដែលបង្ហាញអំពីធាតុផ្សំយុត្តាធិការ ដូចជាការវាយប្រហារជាប្រព័ន្ធនិងជាទូទៅលើប្រជាជនស៊ីវិល។

៣៥. ដូចដែលសហចៅក្រមស៊ើបអង្កេត បានរៀបរាប់លម្អិតនៅកថាខណ្ឌទី៩ នៃដីកាបដិសេធសំណើសុំដោះលែងឲ្យមានសេរីភាព យ៉ាងតិចណាស់ចម្លើយសាក្សីចំនួន១២ ដែលធ្វើឡើងនៅចំពោះមុខអ្នកស៊ើបអង្កេតរបស់ក.ស.ស នៅចន្លោះខែតុលា ឆ្នាំ២០០៧ និងខែមីនា ឆ្នាំ២០០៨ និងភស្តុតាងផ្សេងទៀត បានបញ្ជាក់អំពីការដឹងឮរបស់ជនត្រូវចោទ និងការចូលរួមរបស់គាត់នៅក្នុងឧក្រិដ្ឋកម្មដែលចោទប្រកាន់លើរូបរបស់គាត់[68]។

៣៦. (បានលុបចេញ) [69] [70] [71]។

---

[65] (បានលុបចេញ)

[66] (បានលុបចេញ)

[67] (បានលុបចេញ)

[68] ដីកាបដិសេធសំណើសុំឲ្យដោះលែងមានសេរីភាព C 40/4។ (បានលុបចេញ)

[69] (បានលុបចេញ)

[70] (បានលុបចេញ)

៣៧. ជាចុងក្រោយ យើងត្រូវលើកឡើងថា នៅពេលជនត្រូវចោទផ្សេងទៀតបានដាក់សំណើសុំសើុបអង្កេត ម្ចាស់បណ្តឹងឧទ្ធរណ៍មិនបានដាក់សំណើនេះទេ ហើយសហចៅក្រមស៊ើបអង្កេតមិនបានរកឃើញភស្តុតាងដោះបន្ទុកសំខាន់ណា ដើម្បីអាចទាត់ចោលនូវការសម្រេច អំពី "អត្ថិភាពនៃមូលហេតុដែលត្រូវបានរកឃើញ"នោះទេ។ រហូតមកដល់សព្វថ្ងៃនេះ ម្ចាស់បណ្តឹងឧទ្ធរណ៍ មិនបានដាក់ឯកសារណាមួយទាល់តែសោះ កុំថាឡើយដល់ឯកសារដោះបន្ទុក នៅក្នុងសំណុំរឿង ដែលអាចនាំឱ្យយើងយកការសម្រេចនេះមកពិចារណាឡើងវិញលើការឃុំខ្លួនបណ្តោះអាសន្ន។

## ង. វិធាន ៦៣ (៣) (ខ)៖ ការឃុំខ្លួនបណ្តោះអាសន្ន គឺជាវិធានការចាំបាច់

៣៨. ម្ចាស់បណ្តឹងឧទ្ធរណ៍មិនបានបញ្ជាក់អំពីការប្រែប្រួលស្ថានភាពអង្គហេតុណាមួយ ដើម្បីបង្ហាញថា លក្ខខណ្ឌចាំបាច់ក្នុងការឃុំខ្លួនគាត់តាមវិធាន ៦៣(៣)(ខ) មិនបានបំពេញនោះទេ (សូមមើលខាងលើ កថាខណ្ឌ២៣-២៧) លើកលែងតែការសម្អាងលើពាក្យថា "ការផុតកំណត់នៃរយៈពេលឃុំខ្លួនស្របច្បាប់តែប៉ុណ្ណោះ"។

៣៩. បន្ថែមពីលើនេះទៀត នៅក្នុងបណ្តឹងឧទ្ធរណ៍នេះ សហមេធាវីការពារក្តីមិនបានលើកឡើងអំពីអត្ថិភាពនៃលក្ខខណ្ឌជម្រើស និងដោយឡែក នៃវិធាន ៦៣(៣) (ខ) ក្នុងការកំណត់ថាតើការឃុំបណ្តោះអាសន្នគឺជាវិធានការចាំបាច់ដើម្បី (១) រារាំងកុំឱ្យចុងចោទសង្កត់ទៅលើសាក្សីឬជនរងគ្រោះ (២) ថែរក្សាភស្តុតាង ឬការពារមិនឱ្យបំផ្លាញភស្តុតាង (៤) ការពារសន្តិសុខឱ្យចុងចោទ ឬ (៥) រក្សាសណ្តាប់ធ្នាប់សាធារណៈ។ សហមេធាវីការពារក្តី គ្រាន់តែយោងទៅលើទឡ្ហីករណ៍ដែលខ្លួនបានដាក់នៅក្នុងសំណើ ដែលត្រូវបានសហចៅក្រមស៊ើបអង្កេតបដិសេធរួចហើយ[72]។ ហេតុដូចនេះ សហព្រះរាជអាជ្ញាបានដាក់បញ្ចូលអំណះអំណាងយោង

---

[71] (បានលុបចេញ)

[72] បណ្តឹងឧទ្ធរណ៍ C26/5/1 កថាខណ្ឌទី៦០ យោងទៅលើពាក្យសុំបន្ទាន់ស្នើសុំដោះលែងឱ្យមានសេរីភាពរបស់សហមេធាវីការពារក្តី C 40, ERN 00228906-18 កថាខណ្ឌទី៣៦-៤២ និងទី៤៦-៨២។

ដែលមានចែងនៅក្នុងកថាខណ្ឌទី៥៣ ដល់ទី៧៣ នៃ "ចម្លើយតបនឹងបណ្ដឹងឧទ្ធរណ៍របស់ ខៀវ សំផន ប្រឆាំងនឹងដីកាឃុំខ្លួនបណ្ដោះអាសន្ន"[73] និង កថាខណ្ឌទី១៥ ដល់ទី២៥ នៃ ចម្លើយតបទៅនឹងដីកាបញ្ជូនសំណុំរឿងទៅពិនិត្យ លើពាក្យសុំបន្ទាន់ស្នើសុំដោះលែងឱ្យមាន សេរីភាពរបស់ ខៀវ សំផន ចុះថ្ងៃទី២៤ ខែតុលា ឆ្នាំ២០០៨[74]។ សហព្រះរាជអាជ្ញាក៏បាន យោងទៅលើដីការបស់សហចៅក្រមស៊ើបអង្កេតបដិសេធសំណើសុំដោះលែងឱ្យមានសេរីភាព ចុះថ្ងៃទី២៨ ខែតុលា ឆ្នាំ២០០៨ កថាខណ្ឌទី១៥ ដល់ទី២១[75]។

៤០. ដោយពិចារណាលើការគម្រាមកំហែងចំពោះសន្តិសុខផ្ទាល់ខ្លួន និងសណ្ដាប់ធ្នាប់សាធារណៈ ដែលមានចែងនៅក្នុងមាត្រា ៦៣(៣) (ខ) (៤) និង(៥) សេចក្ដីថ្លែងការណ៍ថ្មីៗ និងឥរិយាបថ របស់ជនរងគ្រោះមួយចំនួន ឬដើមបណ្ដឹងរដ្ឋប្បវេណី បង្ហាញថា ការដោះលែងជនត្រូវ ចោទទាំងប្រាំឱ្យមានសេរីភាព អាចបង្កឱ្យមានអំពើហិង្សា ដោយផ្ទាល់ប្រឆាំងអតីតមេដឹកនាំ ខ្មែរក្រហម រួមមានម្ចាស់បណ្ដឹងឧទ្ធរណ៍ ក្រុមមេធាវីការពារក្ដី ឬអ.វ.ត.ក។ នៅក្នុងអត្ថបទ បោះពុម្ពផ្សាយនៅក្នុងកាសែត New York Times នៅថ្ងៃទី១៧ ខែមិថុនា ឆ្នាំ២០០៨[76] ជន រងគ្រោះចំនួនពីរនាក់បាននិយាយថា ពួកគេចង់ "កាប់ (នួន ជា) ជាចម្រៀកៗ និងចាក់អំបិល លើរបួសរបស់វា (...) វាយដំលើវា និងធ្វើទារុណកម្មវា និងឆក់ខ្សែភ្លើងដើម្បីធ្វើឱ្យវានិយាយ" និងចង់ធ្វើឱ្យពួកវា (ជនត្រូវចោទ) "ឈឺចាប់ដូចអ្វីដែលខ្ញុំឈឺចាប់" នឹងរហូតទាល់តែ "សម្លាប់ ពួកវាចោលតែម្ដងទើបខ្ញុំមានអារម្មណ៍ស្ងប់"។ ជនបីនាក់ បានលើកឡើងជាថ្មីអំពីសេចក្ដី ថ្លែងការណ៍/ការគម្រាមកំហែងរបស់ខ្លួន (ប្រឆាំងនឹង ខៀវ សំផន និងក្រុមមេធាវីការពារក្ដី

---

[73] ចម្លើយតបរបស់សហព្រះរាជអាជ្ញាទៅនឹងបណ្ដឹងឧទ្ធរណ៍របស់ ខៀវ សំផន ប្រឆាំងនឹងដីកាឃុំខ្លួនបណ្ដោះអាសន្នចុះ ថ្ងៃទី១៩ ខែវិច្ឆិកា ឆ្នាំ២០០៧ នៅថ្ងៃទី៦ ខែកុម្ភៈ ឆ្នាំ២០០៨ C26/I/9, ERN 00160767-795 (ភាសាអង់គ្លេស)។

[74] ចម្លើយតបទៅនឹងដីកាបញ្ជូនសំណុំរឿងទៅពិនិត្យលើពាក្យសុំបន្ទាន់ស្នើសុំដោះលែងឱ្យមានសេរីភាពរបស់ ខៀវ សំផន ចុះថ្ងៃទី២៤ ខែតុលា ឆ្នាំ២០០៨ C40/3 ERN 00234631-45 (ភាសាអង់គ្លេស)។

[75] ដីកាបដិសេធសំណើសុំដោះលែងឱ្យមានសេរីភាព C40/4។

[76] "នៅក្នុងតុលាការកាត់ទោសខ្មែរក្រហម ជនរងគ្រោះនឹងមិនត្រូវឈរដោយឥតប្រយោជន៍នោះទេ" ចុះថ្ងៃទី១៧ ខែមិថុនា ឆ្នាំ២០០៨ ដោយ Seth Mydans *កាសែត The New York Times* អាចពិនិត្យបានតាមអាសយដ្ឋានវិបសាយ http://www.nytimes.com/2008/06/17/world/asia/17cambodia.html?scp=1&sq=Seth%20Mydans%20in%20Khmer%20Rouge%20%Trial%20Victims&st=cse នៅថ្ងៃទី៤ ខែមករា ឆ្នាំ២០០៩។

របស់គាត់ និងប្រឆាំងនឹងតុលាការផងដែរ) នៅក្នុងសន្និសិទ្ធិកាសែតដែលធ្វើឡើងក្រោយសវនាការបស់អង្គបុរេជំនុំជម្រះ កាលពីថ្ងៃទី០៤ ខែធ្នូ ឆ្នាំ២០០៨[77]។ ប្រតិកម្មសតិអារម្មណ៍ទាំងនេះគឺជារោគសញ្ញានៃជំងឺបាក់ស្បាត ដែលជនរងគ្រោះនៅមាននៅឡើយ នៅពេលដែលនីតិវិធីអ.វ.ត.ក បាននាំឲ្យមានការផ្ទុះកំហឹងក្រេវក្រោធឡើងវិញ[78]។ ដូច្នេះការគម្រាមកំហែងដល់សណ្តាប់ធ្នាប់សាធារណៈ និងសន្តិសុខផ្ទាល់របស់ជនត្រូវចោទ គឺពិតជាមាន និងនៅតែបន្តមានយ៉ាងពិតប្រាកដ។

---

[77] ដូចដែលវីដេអូសន្និសិទកាសែតអ.វ.ត.ក ចុះថ្ងៃទី៤ ខែធ្នូ ឆ្នាំ២០០៨បានបង្ហាញ ជនរងគ្រោះខ្មែរក្រហមភេទស្រីលើកទីមួយ បានស្រែក និងយកដៃចង្អុលសហមេធាវីការពារក្តីជាតិក្នុងអំឡុងពេលសន្និសិទ។ នៅក្នុងអំឡុងពេលសន្និសិទកាសែតរបស់ជនរងគ្រោះ លី ម៉ូនីសារ (Ly Monysar) ដែលគាត់ជាជនរងគ្រោះ និងបច្ចុប្បន្នជាសន្តិសុខ បានគម្រាមតុលាការ ចំពោះការប្រើប្រាស់សកម្មភាពភេរវកម្មប្រឆាំងនឹងមេដឹកនាំខ្មែរក្រហម "ប្រសិនបើតុលាការនៅតែបន្តលេងកំប្លែងបន្តទៀត" និងដើមបណ្តឹងរដ្ឋប្បវេណីភេទស្រីម្នាក់ (អ្នកដាក់ពាក្យសុំ) ឈ្មោះ សុក ជា (Sok Chear) បានលើកឡើងវិញថា ប្រសិនបើគាត់អាចចាប់ខៀវ សំផនបាន គាត់នឹង "ហែកខៀវ សំផន ហើយយកមកស៊ី"។ សូមមើល "តុលាការខ្មែរក្រហម៖ : l'exaspération des victims intensifiées par un clash avec la défense" ចុះថ្ងៃទី៥ ខែធ្នូ ឆ្នាំ២០០៨, Ka-Set (site d'information sur le Cambodge), Stéphanie Gée, អាចពិនិត្យនៅអាសយដ្ឋានវ៉ិបសាយ http://ka-set.info/index2.php?option=com_content&task=view&id=783&pop=1&page=0&Itemid=46។ "ការលេងសើចនឹងយុត្តិធម៌នៅតុលាការខ្មែរក្រហម" *កាសែត The Nation (New York, USA),* Barbar Crossette ថ្ងៃទី១៧ ខែធ្នូ ឆ្នាំ២០០៨ កថាខណ្ឌទី៤។ "តុលាការខ្មែរក្រហមបានបើកសវនាការលើបណ្តឹងឧទ្ធរណ៍របស់ ខៀវ សំផន ប្រឆាំងនឹងសេចក្តីសម្រេចបកប្រែសំណុំរឿង" ចុះថ្ងៃទី ៥ ខែធ្នូ ឆ្នាំ២០០៨ បកប្រែជាភាសាអង់គ្លេស *កាសែតរស្មីកម្ពុជា* ឆ្នាំទី១៦ លេខ៤៧៦០។ "ភាពឥតសណ្តាប់ធ្នាប់នៅក្នុងតុលាការនៅពេលសវនាការបញ្ចប់ដោយច្របូកច្របល់" ចុះថ្ងៃទី៥ ខែធ្នូ ឆ្នាំ២០០៨ *កាសែតភ្នំពេញប៉ុស្តិ៍* ដោយ Georgia Wilkins។ "Le Cirque Vergès" ចុះថ្ងៃទី១១-១៧ ខែធ្នូ ឆ្នាំ២០០៨ *កាសែតCambodge Soir* ដោយ Adrien Le Gal។ វីដេអូខ្លីៗទាំងបួននៃសន្និសិទ អាចរកបាននៅអ.វ.ត.ក ផ្នែកG តាមកាលបរិច្ឆេទនៃការផ្សព្វផ្សាយរៀងៗខ្លួន (G:\Public Affairs\Daily Clippings International\12. Dec)។

[78] Rob Savage បាននិយាយថា ការចាប់ផ្តើមសកម្មភាពតុលាការចំពោះមុខអ.វ.ត.ក "អាចធ្វើឲ្យមានគ្រោះថ្នាក់ជាថ្មីដល់សង្គមកម្ពុជា" ដែលអាច "នាំឲ្យលេចចេញនូវក្តីបារម្ភ និងការកើតឡើងនូវផលវិបាកសង្គមដែលអាចកើតឡើងអមជាមួយគ្នានោះ"។ Rob Savage "វិបល្លាសស្មារតីក្រោយសង្គ្រាម៖ កេរ្តិ៍ដំណែលនៃការឈឺចាប់ និងអំពើហិង្សា" *សារព័ត៌មាន Monthly South Eastern Globe* ខែកក្កដា ឆ្នាំ២០០៧ ទំព័រ២៤-២៧ ERN00153657-61 (ភាសាអង់គ្លេស)។

៤១. ហេតុដូចនេះ សហព្រះរាជអាជ្ញា ស្នើសុំអង្គបុរេជំនុំជម្រះ សម្រេចថា លក្ខខណ្ឌនៃការឃុំខ្លួនតាម វិធាន ៦៣(៣) (ខ) (១) (២) (៤) និង (៥) នៅតែបានបំពេញ និងបន្តបំពេញ ដែលជាហេតុធ្វើឲ្យការបន្តថេរៈវេលា នៃការឃុំខ្លួនម្ចាស់បណ្តឹងឧទ្ធរណ៍បណ្តោះអាសន្ន នៅតែមានយុត្តិកម្មគ្រប់គ្រាន់។

*គ. គ្មានការដាក់ឲ្យស្ថិតនៅក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការ*

៤២. គ្មានការដាក់ឲ្យស្ថិតនៅក្រោមការត្រួតពិនិត្យនឹងមានលក្ខណៈម៉ឺងម៉ាត់គ្រប់គ្រាន់ ដើម្បីឆ្លើយតបទៅនឹងតម្រូវការនៃការពារសន្តិសុខផ្ទាល់របស់ជនត្រូវចោទ ការរក្សាសណ្តាប់ធ្នាប់សាធារណៈ និងការរារាំងកុំឲ្យជនត្រូវចោទគាបសង្កត់ទៅលើសាក្សី និងជនរងគ្រោះ និងបំផ្លិចបំផ្លាញភស្តុតាងនោះទេ។

## ៤. សេចក្តីសន្និដ្ឋាន

៤៣. អាស្រ័យហេតុនេះ សហព្រះរាជអាជ្ញាស្នើសុំឲ្យអង្គបុរេជំនុំជម្រះ **បដិសេធ**បណ្តឹងឧទ្ធរណ៍របស់សហមេធាវីការពារក្តីចោលទាំងស្រុង។

ធ្វើនៅភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
នៅថ្ងៃទី២២ ខែមករា ឆ្នាំ២០០៩

**សហព្រះរាជអាជ្ញា**

CO-PROSECUTORS CO-PROCUREURS E.C.C.C. C.E.T.C.

**លោក យ៉េត ចរិយា** **លោក** Robert PETIT

**សហព្រះរាជអាជ្ញារង** **សហព្រះរាជអាជ្ញា**